# មាតិកា


| | |
|---|---|
| **សារពីលោកអគ្គនាយកប្រតិបត្តិ** | **2** |
| **ទស្សនៈវិស័យ និងគោលដៅប្រតិបត្តិការ** | **4** |
| **ព័ត៌មានធនាគារ** | **5** |
| ឧទ្ទេសនាម | **6** |
| ទិដ្ឋភាពទូទៅ | 6 |
| ផលិតផល និងសេវា | 7 |
| រចនាសម្ព័ន្ធ | 11 |
| ក្រុមប្រឹក្សាភិបាល | 11 |
| គណៈគ្រប់គ្រង | 12 |
| **របាយការណ៍របស់គណៈគ្រប់គ្រង** | **13** |
| **របាយការណ៍របស់សវនករឯករាជ្យ** | **20** |
| **របាយការណ៍ហិរញ្ញវត្ថុ** | **22** |
| តារាងតុល្យការ | 22 |
| របាយការណ៍លទ្ធផល | 23 |
| របាយការណ៍ស្តីពីការប្រែប្រួលក្នុងមូលធន | 24 |
| របាយការណ៍ចរន្តសាច់ប្រាក់ | 25 |
| កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 26 |
| **ព័ត៌មានទំនាក់ទំនង** | **67** |


BIDC Be your side, by your hand

# សារពីលោកអគ្គនាយកប្រតិបត្តិ

យោងតាមការចង្អុលបង្ហាញពីនាយករដ្ឋមន្ត្រីវៀតណាម ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម (BIDV) បានបង្ហាញវត្តមានជាផ្លូវការនូវអាជីវកម្ម និងការវិនិយោគរបស់ខ្លួនមកកាន់ប្រទេសកម្ពុជា ចាប់តាំងពីចុងខែ កក្កដា ឆ្នាំ ២០០៩ ដោយបានរៀបចំពិធីសម្ពោធប្រតិបត្តិការធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (BIDC) ។

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី បានដំណើរការជាផ្លូវការនៅដើមខែ កញ្ញា ឆ្នាំ ២០០៩ ដោយត្រូវបានបង្កើតតាមរយៈការរៀបចំរចនាសម្ព័ន្ធជាថ្មីទាំងស្រុងធនាគារវិនិយោគរុងរឿង ដែលជាធនាគារឯកជនមួយនៅក្នុងប្រទេសកម្ពុជា បន្ទាប់មកប្តូរឈ្មោះ និងបង្កើនដើមទុនដល់ ៧០ លានដុល្លារអាមេរិក ដែលក្លាយជាធនាគារពាណិជ្ជលំដាប់ទីពីរផ្នែកទុនលក្ខន្តិកៈរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។

គោលបំណងប្រតិបត្តិការសំខាន់ៗរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី គឺភ្ជាប់ទីផ្សារហិរញ្ញវត្ថុទីផ្សារ វៀតណាម និងកម្ពុជា ផ្តល់កញ្ចប់សេវាហិរញ្ញវត្ថុឥតខ្ចោះដល់បណ្តាក្រុមហ៊ុនវៀតណាមដែលវិនិយោគក្នុងប្រទេសកម្ពុជា និងវិស័យសេដ្ឋកិច្ចផ្សេងទៀតក្នុងទីផ្សារប្រទេសកម្ពុជា រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា។

ដោយមានកេរ្តិ៍ឈ្មោះមានស្រាប់របស់ BIDV ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ត្រូវបានស្គាល់យ៉ាងឆាប់រហ័សដោយទីផ្សារហិរញ្ញវត្ថុ និងធនាគារក្នុងប្រទេសកម្ពុជា។ រួមមាននូវបទពិសោធន៍ នីតិវិធី និងបទដ្ឋានតាមកម្រិតអន្តរជាតិ ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី បានពង្រីកយ៉ាងឆាប់រហ័សប្រតិបត្តិការរបស់ខ្លួន តាមគំរូធនាគារបែបទំនើប និងមាននូវសកម្មភាពជំនាញៗ។

សកម្មភាពអាជីវកម្មរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី បាននាំឲ្យមានប្រាក់ចំណេញចាប់តាំងពីចុងឆ្នាំ ២០០៩។ ក្រោយពីធ្វើប្រតិបត្តិការរយៈពេល ៨ ខែ ទ្រព្យសកម្មសរុបរបស់ធនាគារកើនដល់ ១៥០ លាន ដុល្លារអាមេរិក ទ្វេដងប្រៀបទៅនឹងពេលបង្កើត ព្រមទាំងនឹងកើនឡើងយ៉ាងឆាប់រហ័សនាពេលអនាគតខាងមុខ។

ដើម្បីភ្ជាប់ទីផ្សារហិរញ្ញវត្ថុរវាងប្រទេសវៀតណាម និងប្រទេសកម្ពុជាឲ្យមានប្រសិទ្ធិភាព ជាពិសេសបណ្តាញទូទាត់ ផ្ទាល់រវាងវៀតណាម និងកម្ពុជា ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី បានបើកសាខាថ្មីនៅហូជីមិញ កាលពីចុងខែ ធ្នូ ឆ្នាំ ២០០៩ ដោយអំណោយផលដល់ក្រុមហ៊ុនវៀតណាមដែលវិនិយោគ និងធ្វើពាណិជ្ជកម្មនៅក្នុងទីផ្សារប្រទេសកម្ពុជា រួមចំណែកជម្រុញដល់បណ្តាអាជីវកម្មនាំចូល និងនាំចេញ ដូចដែលបានរំពឹងទុកដោយ រដ្ឋាភិបាលប្រទេសទាំងពីរ។

ក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចជាសកល ប្រទេសកម្ពុជានៅមានស្ថេរភាព និងការអភិវឌ្ឍន៍រឹងមាំ លំហូរទុនក្រៅប្រទេស កំពុងបន្តវិនិយោគក្នុងប្រទេសកម្ពុជា។ សេដ្ឋកិច្ចបានផ្លាស់ប្តូរយ៉ាងខ្លាំង។ ក្រៅពីនេះ វត្តមានរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី បានផ្តល់ផលវិជ្ជមានដល់ទីផ្សារហិរញ្ញវត្ថុ និងរូបិយវត្ថុប្រទេសកម្ពុជា រួមចំណែកបង្កើនប្រតិបត្តិការហិរញ្ញវត្ថុ ដោយធនាគារជាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា។ ដោយមានគោលនយោបាយ ត្រឹមត្រូវ និងបត់បែន អាជីវកម្មជាច្រើននៅក្នុងប្រទេសកម្ពុជា បានជ្រើសរើសធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ជាធនាគារបំពេញផ្តល់សេវាទុន និងហិរញ្ញវត្ថុផ្សេងទៀត ហេតុនេះត្រឹមរយៈពេលខ្លីប៉ុណ្ណោះ អតិថិជនជាច្រើនបានមកកាន់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី។

ដោយមានសក្តានុពលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងមាននូវជោគជ័យរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ភាពនាំមុខរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម ជួយឲ្យធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី បន្តស្រាវជ្រាវ និងអភិវឌ្ឍន៍បណ្តាញអនុវត្តយុទ្ធសាស្រ្ត ពង្រីកអាជីវកម្មក្នុងទីផ្សារដ៏មានសក្តានុពលនេះ។

ការបង្កើតធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី សាខាភ្នំពេញ ដែលជាសាខាដំបូងក្នុងទីផ្សារកម្ពុជា បាន បញ្ជាក់យ៉ាងច្បាស់ពីប្រតិបត្តិការរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ដែលកំពុងធ្វើការពង្រីក បណ្តាញ ផ្តល់សេវាយ៉ាងសកម្មសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា បែរឆ្ពោះទៅកាន់អតិថិជន និងគ្រប់បណ្តាវិស័យសេដ្ឋកិច្ច ជាពិសេសបណ្តាក្រុមហ៊ុនវៀតណាមដែលវិនិយោគក្នុងប្រទេសកម្ពុជា បង្កើតជំហររបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ីជាបណ្តើរៗក្នុងទីផ្សារប្រទេសកម្ពុជា និងរៀបចំលក្ខខណ្ឌចាំបាច់ ដើម្បីក្តាប់បានឱកាសរីកចំរើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានាពេលខាងមុខ ជាពិសេសពេលដែលទីផ្សារភាគហ៊ុនដំណើរការជាផ្លូវការ។

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី សូមប្តេជ្ញាចិត្តចំពោះរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជាថា ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី នឹងធ្វើសមាហរណ៍កម្មយ៉ាងឆាប់រហ័ស និងអភិវឌ្ឍន៍សក្តានុពលរបស់ខ្លួនក្នុងទីផ្សាររបស់ប្រទេសកម្ពុជា រួមចំណែកអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុនិយាយដោយឡែក និងនិយាយជារួម អភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា។

# ទស្សនៈវិស័យ និង

# ទិសដៅប្រតិបត្តិការ

- ជួយអនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដោយភ្ជាប់ទីផ្សារហិរញ្ញវត្ថុរវាងប្រទេសវៀតណាម និងប្រទេសកម្ពុជា។
- ផ្តល់ផលិតផល និងសេវាធនាគារមានគុណភាពខ្ពស់រួមមាន ឥណទាន បញ្ញើ ទូទាត់ជាអន្តរជាតិ ហិរញ្ញប្បទានពាណិជ្ជកម្ម ផលិតផល និងសេវាប័ណ្ណ និងផ្សេងៗទៀតសំរាប់ទីផ្សារមូលបត្រដូចជា @Securities ។
- ភ្ជាប់ពាណិជ្ជកម្ម និងសកម្មភាពវិនិយោគទ្វេភាគី ជម្រុញគុណសម្បត្តិប្រកួតប្រជែងនៃបណ្តាអាជីវកម្មក្នុងទីផ្សារទាំងពីរ រួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទំនាក់ទំនងវិនិយោគរវាងប្រទេសវៀតណាម និងប្រទេសកម្ពុជា។
- បំពេញតម្រូវការសេវាហិរញ្ញវត្ថុ ជាពិសេសសេវាសាច់ប្រាក់ និងទូទាត់របស់បណ្តា អាជីវកម្ម និងឯកត្តជនវៀតណាម និងកម្ពុជា ផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងមូលនិធិរយៈពេលមធ្យម រហូតដល់រយៈពេលវែង ដើម្បីបម្រើជូនដល់សកម្មភាពវិនិយោគរបស់បណ្តាសហគ្រាស ក្រុមហ៊ុនគ្រប់គ្រងដោយរដ្ឋ និងបណ្តាអាជីវកម្ម ផ្សេងៗទៀតរបស់បណ្តាប្រទេសទាំងពីរ។
- ធ្វើជាស្ពានភ្ជាប់វិនិយោគិនខ្មែរ និងបណ្តាសហគ្រាសអាជីវកម្មវៀតណាម។ ផ្តល់សេវាច្រើនប្រភេទសម្រាប់គ្រប់ប្រភេទសហគ្រាស រួមទាំងសហគ្រាសប្រទេស និងឯកត្តជនផងដែរ។

BIDC Be your side, by your hand

# ព័ត៌មានធនាគារ

| | |
|---|---|
| ឈ្មោះ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី |
| ឈ្មោះអក្សរកាត់ | BIDC |
| ទុនលក្ខន្តិកៈ | 70 លានដុល្លារអាមេរិក |
| អសយដ្ឋាន | លេខ 23 ផ្លូវលេខ 114 កែងផ្លូវលេខ 67 សង្កាត់ផ្សារថ្មី 2 ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ទូរស័ព្ទ<br>ទូរសារ<br>គេហទំព័រ<br>អ៊ីម៉ែល<br>លេខ SWIFT | (855-23)210 044<br>(855-23) 220 511<br>www.bidc.com.kh<br>info@bidc.kh<br>IDBCKHPP |
| ភាគទុនិក | ក្រុមហ៊ុនវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា អាយ.ឌី.ស៊ី.ស៊ី ទុន 100% |
| ប្រធានក្រុមប្រឹក្សាភិបាល | លោក Tran Thanh Van |
| អគ្គនាយកប្រតិបត្តិ | លោក Nguyen Van Hien |
| លេខអាជ្ញាប័ណ្ណ<br>ប្រភេទ | លេខ 19<br>អាជ្ញាប័ណប្រតិបត្តិការធនាគារ |
| ក្រុមហ៊ុនសវនកម្ម | ក្រុមហ៊ុន Ernst & Young |
| រូបសញ្ញា | BIDC Be your side, by your hand |

# ឧទ្ទេសនាម

## ទិដ្ឋភាពទូទៅ

ឈរលើមូលដ្ឋានការចង្អុលណែនាំ និងការគាំទ្ររួមគ្នា ពីរដ្ឋាភិបាលវៀតណាម និងកម្ពុជា ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម (BIDV) និងក្រុមហ៊ុន ហឿងណាំ (ដែលទាំងពីរ នេះគឺជានីតិបុគ្គលរបស់ប្រទេសវៀតណាម) បានរួមគ្នាបង្កើតក្រុមហ៊ុនវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា អាយឌីស៊ីស៊ី (I.D.C.C) នៅក្នុងប្រទេសកម្ពុជា ដើម្បីធ្វើសកម្មភាពធនាគារហិរញ្ញវត្ថុ និងធានារ៉ាប់រងដោយគម្រោងដំបូងគឺ ការទិញយកធនាគារវិនិយោគរុងរឿង ភីអិលស៊ី (ដែលជាធនាគារតូច មាននៅក្នុងប្រទេសកម្ពុជា បង្កើតឡើងដោយភាគទុនិកជារូបវន្តបុគ្គលក្នុងឆ្នាំ ២០០៧) រៀបចំរចនាសម្ព័ន្ធទាំងស្រុងឡើងវិញ និងប្តូរឈ្មោះធនាគារជាថ្មីទៅជា ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអីលស៊ី (ប៊ីអាយឌីស៊ី) ដែលត្រូវបានអនុម័តយល់ព្រមដោយធនាគារជាតិនៃកម្ពុជា តាមសេចក្តីសម្រេចលេខ ធ១.០៩.៥៥៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩។

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអីលស៊ី បានប្រតិបត្តិការជាផ្លូវការរបស់ខ្លួនចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩ បន្ទាប់ពីទទួលបានលិខិតយល់ព្រមលេខ ធ៧.០៩.១៤៨ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩ របស់ធនាគារជាតិនៃគម្ពុជា ឲ្យប្តូរឈ្មោះ បង្កើនទុនលក្ខន្តិកៈ ផ្លាស់ប្តូរមន្ត្រីបង្គោលធនាគារ។ ដោយការបង្កើតចេញពីការទិញ និងរៀបចំរចនាសម្ព័ន្ធ ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអីលស៊ី គឺជាធនាគារដែលមានដើមទុន ១០០% ដោយរដ្ឋាភិបាលវៀតណាម ដែលត្រូវបានបង្កើត និងអនុញ្ញាតឲ្យធ្វើសកម្មភាពក្នុងទីផ្សារប្រទេសកម្ពុជា ដើម្បីអនុវត្តកាតព្វកិច្ចដាក់ជូនដោយរដ្ឋាភិបាលប្រទេសទាំងពីរ។ ធនាគាររំពឹងទុកថា នឹងក្លាយជាស្ពានភ្ជាប់ទីផ្សារហិរញ្ញវត្ថុ និងធនាគាំរវាងប្រទេសទាំងពីរ។

យោងតាមតាមលក្ខន្តិកៈ ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអីលស៊ី គឺជាស្ថាប័នហិរញ្ញវត្ថុដែលត្រូវបានបង្កើតឡើង និងប្រតិបត្តិការយោងតាមច្បាប់ប្រទេសកម្ពុជា និងបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ ប្រតិបត្តិការជំនាញរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអីលស៊ី ត្រូវបានគាំទ្រដោយផ្ទាល់ពី ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម ដែលមានបទពិសោធន៍ធនាគារជាង ៥០ ឆ្នាំ ក្នុងទីផ្សារហិរញ្ញវត្ថុប្រទេសវៀតណាម។ ការគាំទ្ររបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម ចំពោះធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអីលស៊ី មានច្រើនវិស័យ ជាពិសេសប្រព័ន្ធបច្ចេកវិទ្យា ដំណើរការជំនាញ និងផលិតផល ព្រមទាំងសេវាធនាគារជឿនលឿនប្រកបដោយគុណភាពខ្ពស់។

Be your side, by your hand

# ផលិតផល និងសេវា

## អតិថិជនឯកត្តជន

### ចល័តទុន

- ***គណនីចរន្តជាដុល្លារ រៀល និងរូបិយប័ណ្ណផ្សេងទៀត :*** គឺជាគណនីសំរាប់អ្នកប្រើប្រាស់ដែលបើកនៅធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ីសំរាប់ផ្ញើរប្រាក់ រក្សាប្រាក់ ឬបង់ប្រាក់តាមមធ្យោបាយទូទាត់។
- ***បញ្ញើមានកាលកំណត់ :*** អតិថិជនអាចជ្រើសរើសរយៈពេល និងការប្រាក់។ ជាមួយនឹងផលិតផលនេះ អតិថិជនអាចដកប្រាក់ តែនៅពេលចប់រយៈពេលប៉ុណ្ណោះ បន្ទាប់ពីមានការព្រមព្រៀងជាមួយធនាគារ។

### ផ្ទេរប្រាក់

- ***ផ្ទេរចូលក្រៅប្រទេស :*** ជាសេវាដែលផ្ទេរប្រាក់ចូលគណនីអ្នកទទួលប្រាក់នៅធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ទទួលការទូទាត់ជាសាច់ប្រាក់ ឬផ្ទេរប្រាក់ចូលធនាគារដែលបានកំណត់ ក្នុងករណីអតិថិជនមិនមានគណនីនៅ ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី។
- ***ផ្ទេរចេញក្រៅប្រទេស :*** ជាសេវាសំរាប់គោលបំណងទូទាត់ គណនីប្រតិបត្តិការ ប្រតិបត្តិការទុន អនុវត្តតាមច្បាប់ប្តូរប្រាក់។
- ***ផ្ទេរចេញក្នុងប្រទេស :*** ជាសេវាដែលអតិថិជនអាចជូនដំណឹងឱ្យធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ផ្ទេរប្រាក់ឱ្យអ្នកទទួលប្រាក់ក្នុងប្រទេស។ ធនាគារវិនិយោគ និងអភិឌ្ឍន៍កម្ពុជា ភីអិលស៊ី ធ្វើការទូទាត់ដល់សាខានៅក្នុង ឬក្រៅប្រព័ន្ធធនាគារវិនិយោគ និងអភិឌ្ឍន៍កម្ពុជា ភីអិលស៊ី នៅក្នុងប្រទេសកម្ពុជា។
- ***ផ្ទេរចូលក្នុងប្រទេស :*** ជាសេវាដែលផ្ទេរប្រាក់ចូលគណនីអ្នកទទួលប្រាក់នៅធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ទទួលការទូទាត់ជាសាច់ប្រាក់ ឬផ្ទេរប្រាក់ចូលធនាគារដែលបានកំណត់ ក្នុងករណីអតិថិជនមិនមានគណនីនៅ ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី។
- ***មូលប្បទានប័ត្រទេរ និងការទូទាត់តាមសេវាមូលប្បទានប័ត្រ :*** ជាសេវាដែលធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ផ្តល់តាមតំរូវការអិតថិជន ដោយអនុវត្តតាមបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា

### សេវាឥណទាន

- ***កម្ចីទិញផ្ទះ :*** ជាផលិតផលដែលធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ផ្តល់ប្រាក់ជូនដើម្បីទិញផ្ទះ ដី ឬសាងសង់ផ្ទះថ្មី។

- ***កម្ចីទិញរថយន្ត*** **:** ជាផលិតផលដែលបំពេញតាមតំរូវការធ្វើជាម្ចាស់រថយន្តដោយខ្លួនឯង អតិថិជនគ្រាន់តែតំរូវឱ្យមានប្រាក់កម្រិតអប្បបរមាតាមការកំណត់របស់ធនាគារ (បញ្ចាំរថយន្តដែលទិញ ឬទ្រព្យធានាផ្សេងទៀត) ។

- ***កម្ចីអាជីវកម្ម*** **:** ជាផលិតផលដែលផ្តល់ទុន ដើម្បីវិនិយោគ និងផលិតទំនិញរបស់អាជីវកម្ម ។

- ***កម្ចីដោយដាក់បញ្ចាំប័ណ្ណដាក់ប្រាក់បញ្ញើ*** **:** ត្រូវបានប្រើប្រាស់សំរាប់អ្នកដែលមានប័ណ្ណដាក់ប្រាក់បញ្ញើនៅក្នុងធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ដើម្បីបំពេញតំរូវការទុនឱ្យបានឆាប់ នៅពេលដែលប័ណ្ណមិនទាន់ផុតកំណត់ ។

### សេវាផ្សេងៗ

- ***ប័ណ្ណអេធីអឹម*** **:** ប័ណ្ណអេធីអឹម គឺជាមធ្យោបាយទូទាត់ដែលឿនលឿន និងងាយស្រួល ហើយវាក៏បង្ហាញពីការអភិវឌ្ឍន៍សកម្មភាពទូទាត់ និងជាពិសេសជាការទទួលយកនូវបច្ចេកវិទ្យាធនាគារផងដែរ ។ អតិថិជនក៏អាចប្រើប្រាស់ប័ណអេធីអឹម ដើម្បីដកប្រាក់ ទូទាត់តាមម៉ាស៊ីនភីអូអេសរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី និងដើម្បីទទួលបានសេវាផ្សេងទៀតដែលធនាគារផ្តល់ជូនផងដែរ ។

- **BIDC – Directbanking** : ជាសេវាទំនើបដែលអតិថិជនអាចពិនិត្យគណនីរបស់ខ្លួននៅធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី តាមអ៊ិនធ័រណេត ។

## អតិថិជនក្រុមហ៊ុន

អតិថិជនក្រុមហ៊ុនរួមមាន អាជីវកម្ម អង្គភាពនយោបាយ អង្គការសង្គម ច្បាប់ ដែលត្រូវបានបង្កើតឡើងស្ថិតក្រោមច្បាប់ប្រទេសកម្ពុជា និងស្ថាប័ននៅក្រៅប្រទេសផ្សេងទៀត ។

### សេវាគ្រប់គ្រងគណនី

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ទទួលបញ្ញើ គ្រប់គ្រង និងតាមដានតុល្យភាព ព្រមទាំងផ្តល់សេវាគ្រប់គ្រងគណនី ឱ្យអតិថិជនបានយ៉ាងឆាប់រហ័ស សុវត្ថិភាព និងត្រឹមត្រូវ ។ នៅពេលដាក់ប្រាក់នៅធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី អតិថិជន នឹងបើកនូវគណនីដូចខាងក្រោម :

គណនីចរន្ត (C/A)

គណនីសំចៃ (S/A)

### សេវាទូទាត់បៀវត្សស្វ័យប្រវត្តិ

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ផ្តល់សេវាដូចជា ការទូទាត់បៀវត្សស្វ័យប្រវត្តិ ភាគលាភ ទូទាត់ទំនិញឱ្យអ្នកទទួលដោយមិនគិតថាតើពួកគេមានគណនីនៅធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ឬអត់នោះឡើយ ។

សំរាប់សេវាទាំងនេះ ធនាគារវិនិយោគ និងអភិវឌ្ឍន៏កម្ពុជា ភីអិលស៊ី នឹងទូទាត់ប្រាក់ឱ្យបុគ្គល (ឬក្រុមហ៊ុន) ក្នុងប្រតិបត្តិការ បន្ទាប់ពីការបង្គាប់ឱ្យទូទាត់ (អតិថិជនរបស់ធនាគារ) ដូចខាងក្រោម :

ក្រុមហ៊ុនបង់បៀវត្ស និងរង្វាន់ជូនបុគ្គលិក

ក្រុមហ៊ុនត្រូវទូទាត់ទំនិញសំរាប់សេវាដែលបានផ្តល់ជូនដូចជា ផ្សារទំនើប ក្រុមហ៊ុនអាជីវកម្មទូទៅ ។ល។

ក្រុមហ៊ុនមានប្រព័ន្ធភ្នាក់ងារធំ ហើយពួកគេត្រូវទូទាត់រង្វាន់ឱ្យភ្នាក់ងារទាំងនោះ ។ល។

## សេវាទូទាត់ក្នុងប្រទេស

ធនាគារវិនិយោគ និងអភិវឌ្ឍន៏កម្ពុជា ភីអិលស៊ី ទទួលការទូទាត់ក្នុងប្រទេស ដែលចាំបាច់ត្រូវដាក់ប្រាក់ចូលគណនីចរន្តរបស់អតិថិជន (ឬជាសាច់ប្រាក់) នៅតាមសាខារបស់ធនាគារ ។ ការបង្គាប់ឱ្យទូទាត់ ត្រូវបានធ្វើឡើងដូចខាងក្រោម :

បង់ប្រាក់ទៅគណនីរបស់អតិថិជន ។

ឬជូនដំណឹងឱ្យអតិថិជនតាមលេខទូរស័ព្ទ និងអសយដ្ឋានរបស់អតិថិជន

## សេវាទូទាត់ការនាំចូល និងនាំចេញ

ធនាគារវិនិយោគ និងអភិវឌ្ឍន៏កម្ពុជា ភីអិលស៊ី ផ្តល់ជូនសេវាទូទាត់ការនាំចូល និងនាំចេញឱ្យអតិថិជន រួមមាន :

- ***សេវាទូទាត់ការនាំចូល :***

ចេញ L/C – កែ L/C

បញ្ជាក់ L/C

ប្រមូលឯកសារនាំចូល

- ***សេវាទូទាត់ការនាំចេញ :***

ជូនដំណឹងពី L/C និងការកែប្រែ

ប្រឹក្សាពីចំណុចដែលមានក្នុង L/C

រៀបចំឯកសារនាំចេញសំរាប់ទូទាត់

អប្បហារឯកសារ

## ឥណទានក្រុមហ៊ុន

គ្រប់ក្រុមហ៊ុន អាចទទួលបានទុនជាឥណទាននេះ តាមរយៈផលិតផលជម្រើសជាច្រើន ។ អតិថិជន នឹងត្រូវបានណែនាំដើម្បីរៀបចំឯកសារចាំបាច់ឱ្យបានឆាប់ ដោយមិនគិតថ្លៃប្រឹក្សា ។

អតិថិជនងាយស្រួលខ្ចីទុន ដើម្បីទិញ និងសាងសង់អគារថ្មី ជួសជុល និងកែលំអអគារចាស់ ទូទាត់ក្នុងស្រុក និងទូទាត់ក្រៅប្រទេសពាក់ព័ន្ធនឹងសកម្មភាពខាងលើនេះ ។

អតិថិជនងាយស្រួលទិញទំនិញ វត្ថុធាតុដើម ឥន្ធនៈ និងគ្រឿងបន្លាស់ បង់ថ្លៃពន្ធ ថ្លៃអគ្គិសនី និងបៀវត្ស ទូទាត់ចូល និងចេញពាក់ព័ន្ធនឹងសកម្មភាពខាងលើនេះ។

## ការធានា

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ផ្តល់ជូនអតិថិជននូវសេវាធានារួមមាន :

- ធានាខ្ចីទុន
- ធានាខ្ចីទុនក្នុងស្រុក
- ធានាខ្ចីទុនក្រៅប្រទេស
- ធានាទូទាត់
- ធានាដេញថ្លៃ
- ធានាអនុវត្តកិច្ចសន្យា
- ធានាគុណភាពផលិតផល
- ធានាទូទាត់មុន
- ធានាច្រើនប្រភេទទៀត

## សេវាផ្សេងៗ

ក្រៅពីនេះ ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ក៏ផ្តល់ជូននូវសេវាធានាផ្សេងទៀត គាំទ្រដល់សេវាសំរាប់បណ្តាក្រុមហ៊ុន ដែលវិនិយោគនៅក្នុងប្រទេសវៀតណាមផងដែរ។

BIDC Be your side, by your hand

# ក្រុមប្រឹក្សាភិបាល

**លោក Tran Thanh Van:** **ប្រធានក្រុមប្រឹក្សាភិបាល**



- ឆ្នាំកំណើត : 1961
- ការសិក្សា : បរិញ្ញាបត្រ
- បទពិសោធន៍ :

10/1991: អគ្គនាយករង BIDV Quangnam – Danang Branch, Vietnam

04/1991: អគ្គនាយក BIDV Danang Branch, Vietnam

09/2009: អនុប្រធានក្រុមប្រឹក្សាភិបាល BIDV, Vietnam

| | |
|---|---|
| **លោក Nguyen Tien Bac** | អនុប្រធានក្រុមប្រឹក្សាភិបាល |
| **លោក Nguyen Van Hien** | សមាជិក |
| **លោក Pham Van Duong** | សមាជិក |
| **លោកស្រី Le Thanh Van** | សមាជិកឯករាជ្យ |
| **លោក Tran Dinh Dinh** | សមាជិកឯករាជ្យ |

BIDC Be your side, by your hand

# គណៈគ្រប់គ្រង

**លោក Nguyen Van Hien:** **អគ្គនាយកប្រតិបត្តិ**



- **ឆ្នាំកំណើត :** 1961
- **ការសិក្សា :** បរិញ្ញាបត្រនៅ HoChiMinh Banking University, Vietnam; ថ្នាក់ក្រោយឧត្តមសិក្សានៅ HoChiMinh Economics University, Vietnam; បរិញ្ញាបត្រនៅ HoChiMinh National Institute of Polictics, Vietnam; អនុបណ្ឌិត Banking and Finance, Help University, Malaysia.
- **បទពិសោធន៍ :**

08/1999: អគ្គនាយករង និងជានាយក BIDV Transaction Center No.II, Vietnam

08/2002: អគ្គនាយករង និងជានាយករងសាខា BIDV Saigon Branch, Vietnam

03/2003: អគ្គនាយករង និងជានាយកសាខា Lao-Viet bank's Ho Chi Minh, Vietnam

07/2008: សមាជិកក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកប្រតិបត្តិ Lao-Viet Bank, Laos

| | |
|---|---|
| **លោកស្រី Mai Thi Ngoc Ha** | **អគ្គនាយករងទី ១** |
| **លោក Pham The Nghiem** | **អគ្គនាយករង** |
| **លោក Mey Phy** | **អគ្គនាយករង** |
| **លោក Pham Van Duong** | **អគ្គនាយករង** |

**លោកស្រី Mai Thi Ngoc Ha:** **នាយកគណនេយ្យ**



- **ឆ្នាំកំណើត :** 1963
- **ការសិក្សា :** បរិញ្ញាបត្រសេដ្ឋកិច្ច HoChiMinh Banking University, Vietnam; IT Engineering, HoChiMinh University of Technology, Vietnam
- **បទពិសោធន៍ :**

2005: អគ្គនាយករង និងជានាយកគ្រប់គ្រងសាច់ប្រាក់ BIDV HoChiMinh Branch, Vietnam

2006: អគ្គនាយករង និងជានាយកហិរញ្ញវត្ថុ និងគណនេយ្យ BIDV North Saigon Branch, Vietnam

# របាយការណ៍របស់
# គណៈគ្រប់គ្រង

គណៈគ្រប់គ្រងសូមបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (“ធនាគារ”) ដែលត្រូវបានស្គាល់ជា ធនាគារវិនិយោគរុងរឿង ភីអិលស៊ី នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និងថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ និងសំរាប់ការិយបរិច្ឆេទ ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩។

## ព័ត៌មានអំពីធនាគារ

ធនាគារវិនិយោគរុងរឿង ភីអិលស៊ី គឺជាសាជីវកម្មធនាគារដែលបានចុះបញ្ជីអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា លេខ 0765 MOC.LAD ដែលចេញដោយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។ ធនាគារ វិនិយោគរុងរឿង ភីអិលស៊ី គឺជាធនាគាពាណិជ្ជធ្វើប្រតិបត្តិការស្ថិតក្រោមអាជ្ញាប័ណ្ណលេខ ១៩ ចេញនៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដោយធនាគារជាតិនៃកម្ពុជា ។ រាល់សកម្មភាពប្រតិបត្តិការរបស់ធនាគារ ត្រូវស្ថិតក្រោមច្បាប់ពាណិជ្ជកម្ម និងសហគ្រាសនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ ស្តីអំពីធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ ធនាគារវិនិយោគរុងរឿង ភីអិលស៊ី ត្រូវបានទិញដោយ ក្រុមហ៊ុន វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ដែលហៅកាត់ថា “IDCC” ដែលជាមានម្ចាស់ភាគហ៊ុនរួមរវាង ធនាគារវិនិយោគ និងអភិវឌ្ឍន៍ វៀតណាម និងក្រុមហ៊ុន Phuong Nam ( ក្រុមហ៊ុនទាំងពីរជាសញ្ជាតិវៀតណាម ) ហើយបានកែទំរង់ និងប្តូរឈ្មោះ មកជា ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី ស្របតាមសេចក្តីសម្រេចលេខ ធ១-០៩-៥៥៤ របស់ អគ្គទេសាភិបាលនៃ ធនាគារជាតិនៃកម្ពុជា ចុះនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ និងមានសុពលភាពចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ តទៅ។

## ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

តាមការរៀបចំឡើងវិញ ធនាគារបានបង្កើតឡើងតាម អាជ្ញាប័ណ្ណថ្មីចេញដោយក្រសួងពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណថ្មីមួយទៀតចេញដោយ ធនាគារជាតិនៃកម្ពុជា ។ BIDC ក៏មានក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រងថ្មីផងដែរ ។ តាមការរៀបចំឡើងវិញនេះ គណៈគ្រប់គ្រងជឿជាក់ថាការិយបរិច្ឆេទហិរញ្ញវត្ថុផ្សេងគ្នាទាំងពីរនេះសំរាប់ឆ្នាំ ២០០៩ គឺការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង សំរាប់ការិយបរិច្ឆេទ ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ( ក្រោយការរៀបចំរចនាសម្ពន្ធ័ឡើងវិញនៃការិយបរិច្ឆេទ ) និង នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៩ និង កាលបរិច្ឆេទថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៩ ដល់ថ្ងៃទី

៣១ ខែកក្កដា ឆ្នាំ ២០០៩ (មុនការរៀបចំរចនាសម្ព័ន្ធឡើងវិញនៃ ការិយបច្ឆេទ) ប៉ុន្តែមិនមានការប្រៀបធៀប ដែលផ្តល់នូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដ៏មានអត្ថន័យមួយ ដោយសារតែការិយបរិច្ឆេទហិរញ្ញវត្ថុគ្របដណ្តប់ ការិយបរិច្ឆេទបន្ទាប់ពីធនាគារត្រូវបានទិញដោយ IDCC និងការិយបរិច្ឆេទ មុនការទិញ ។ ការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដើម្បីគ្របដណ្តប់លើការិយបរិច្ឆេទហិរញ្ញវត្ថុ ត្រូវបានអនុម័ត ដោយធនាគារជាតិនៃកម្ពុជា ដោយយោងតាមលិខិតលេខ ធ៧/១០/៦៩ ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០ ។

## សកម្មភាពចំបងរបស់ធនាគារ

សកម្មភាពចំបងរបស់ធនាគាររួមមាន ការធ្វើប្រតិបត្តិការលើវាល់សកម្មភាពអាជីវកម្មធនាគារ និង ការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗទៀត ។ ពុំមានការផ្លាស់ប្តូរជាសំខាន់លើសកម្មភាពចំបងៗ នៅក្នុងកំឡុងពេលហិរញ្ញវត្ថុនេះ ទេ ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ មានដូចខាងក្រោម:

| | *ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៩ ដុល្លារអាមេរិក* | *ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ ដុល្លារអាមេរិក* |
|---|---|---|
| ប្រាក់ចំណេញមុនដកពន្ធ | ១៤៧,៩៧៣ | (៤,៣៥៥,៣៦១) |
| ពន្ធលើប្រាក់ចំណេញ | (២៩,៥៩៤) | (៨៤៥) |
| **ប្រាក់ចំណេញ /ខាតក្រោយដកពន្ធ - ដុល្លារអាមេរិក** | **១១៨,៣៧៩** | **(៤,៣៥៦,២០៦)** |
| **ប្រាក់ចំណេញ /ខាតក្រោយដកពន្ធ - ពាន់រៀល** | **៤៩៣,៥២០** | **(១៨,២៥៦,៨៦១)** |
| ត្រូវបានបែងចែកដូចខាងក្រោម: | | |
| អ្នកកាន់កាប់មូលធនរបស់ធនាគារ - ពាន់រៀល | ៤៩៣,៥២០ | (១៨,២៥៦,៨៦១) |
| ម្ចាស់ភាគហ៊ុនអប្បភាគ | - | - |

## ភាគលាភ

មិនមានភាគលាភត្រូវបានប្រកាសឬបង់ទេ ហើយព្រមជាមួយនេះគណៈគ្រប់គ្រង ក៏មិនបានណែនាំឱ្យមាន ការបង់ចំណែកភាគលាភក្នុង កំឡុងពេលធ្វើសវនកម្មដែរ ។

**មូលធន**

សមតុល្យដើមទុនរបស់ធនាគារសំរាប់ការិយបរិច្ឆេទនា ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ គឺ ១៣,៥០០,០០០ដុល្លារអាមេរិក។ យោងតាមលិខិតបញ្ជាក់លេខ B7-09-654 ស.ជ.ណ ចុះ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ (ការយល់ព្រមសំរាប់លិខិតស្នើលេខ០៧៩/២០០៩ ធ.វ.អ.ក ប្រគល់ជូនដោយ ធនាគារវិនិយោគ និងអភិវឌ្ឍន៏កម្ពុជា ភីអិលស៊ី នាថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩) ធនាគារជាតិនៃកម្ពុជាបានអនុម័តអោយធនាគារលុបចោលនូវ ការខាតបង់បង្គរទាំងអស់ ចំនួន ១១,៣២៩,៣៧៨ ដុល្លារអាមេរិក កើតឡើងមុនការទិញ (ដែលរួមបញ្ចូលទាំងការខាតបង់ចំនួន ៤,៣៥៦,២០៦ ដុល្លារអាមេរិក នាការិយបរិច្ឆេទ ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ និងការខាតបង់ បង្គរមុនពេលបរិច្ឆេទនោះគឺ ៦,៩៧៣,១៧២ ដុល្លារអាមេរិក មុនការិយបរិច្ឆេទ)។

នាកាលបរិច្ឆេទ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ IDCC បានបណ្តាក់ទុនចំនួន ៦៧,៨២៩,៣៧៨ ដុល្លារអាមេរិក ដើម្បី បន្ថែមទុនដល់ ៧០,០០០,០០០ ដុល្លារអាមេរិក នាកាលបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩។

**ទុនបំរុង និង សំវិធានធន**

ពុំមានការប្រែប្រួលជាសារវ័ន្តទៅលើ ទុនបំរុង និង សំវិធានធននៅក្នុងកាលបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ។

**ឥណទាន និង បុរេប្រទានអាក្រក់និងជាប់សង្ស័យ**

នៅមុនពេលដែលរបាយការណ៏លទ្ធផល និង តារាងតុល្យការរបស់ធនាគារត្រូវបានរៀបចំឡើងដោយ គណៈគ្រប់គ្រងបានចាត់វិធានការណ៏ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទាន និង បុរេប្រទានអាក្រក់ និង ការធ្វើសំវិធានធនលើឥណទាន និង បុរេប្រទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយគណៈគ្រប់គ្រង មានការជឿជាក់ថា រាល់ឥណទាន និង បុរេប្រទានដែលបានដឹងថាមិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយ សំវិធានធនគ្រប់គ្រាន់ត្រូវបានសំគាល់ឡើងសំរាប់ឥណទាន និង បុរេប្រទានដែលជាប់សង្ស័យ នាថ្ងៃចេញរបាយការណ៏ នេះគណៈគ្រប់គ្រងពុំបានដឹងពីហេតុការណ៏ណាមួយដែលនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទាន និង បុរេប្រទានអាក្រក់ឬចំនួននៃការធ្វើសំវិធានធនលើឥណទាន និង បុរេប្រទានជាប់សង្ស័យនៅក្នុងរបាយការណ៏ហិរញ្ញវត្ថុនេះ មានចំនួនមិនគ្រប់គ្រាន់រហូតដល់កំរិតជាសារវ័ន្តណាមួយនោះទេ។

**ទ្រព្យសកម្ម**

នៅមុនពេលដែលរបាយការណ៏លទ្ធផល និង តារាងតុល្យការរបស់ធនាគារ ត្រូវបានរៀបចំឡើងគណៈគ្រប់គ្រងបានចាត់ វិធានការណ៏ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មលើកលែងបំណុលចេញ ដែលបានកត់ត្រា នៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ហើយដែលមិនមានតម្លៃជាក់ស្តែង នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យ នៅស្មើនឹងតម្លៃជាក់ស្តែងដែលបានរំពឹងទុក។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ គណៈគ្រប់គ្រងធនាគារ ពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលអោយការ កំណត់តំលៃនៃទ្រព្យសកម្មរយៈពេលខ្លី នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានការយល់ច្រឡំ ជាសារវន្ត័នោះទេ ។

## វិធីសាស្ត្រវាយតម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ គណៈគ្រប់គ្រងពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការ អនុវត្តវិធីសាស្ត្រ ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យ និង ទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមានភាពមិនត្រឹមត្រូវនិងមិនសមស្របនោះទេ ។

## បំណុលជាយថាហេតុនិងបំណុលផ្សេងៗ

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ:

(ក) គ្មានការទទួលខុសត្រូវដែលកើតចេញពីទ្រព្យ របស់ធនាគារក្នុងការធានាបំណុលរបស់បុគ្គលដទៃ ចាប់ពី កាលបរិច្ឆេទបញ្ចប់ដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ។

(ខ) គ្មានបំណុលជាយថាហេតុទាក់ទងនឹងធនាគារ ដែលបានកើតឡើងចាប់ពីកាលបរិច្ឆេទ នៃកាលបរិច្ឆេទបញ្ចប់ដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រៅពីបំណុលដែលមានទំនាក់ទំនងជាមួយសកម្មភាពប្រក្រតី របស់ធនាគារ នោះទេ ។

ផ្អែកតាមមតិយោបល់របស់គណៈគ្រប់គ្រងធនាគារ គ្មានបំណុលជាយថាហេតុ ឬ បំណុលផ្សេងទៀតរបស់ធនាគារ ដែលអាច ឬ ទំនងក្លាយជាកាតព្វកិច្ចក្នុងកំឡុងកាលបរិច្ឆេទ ១២ ខែខាងមុខ បន្ទាប់ពីកាលបរិច្ឆេទនៃកាលបរិច្ឆេទបញ្ចប់នេះដែលនឹង មាន ឬ អាចមានឥទ្ធិពលជាសារវន្ត័ទៅលើលទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលបំណុលទាំងនោះក្លាយជាបំណុលពិត ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃតារាងតុល្យការ

មិនមានព្រឹត្តិការណ៍ដែលមានឥទ្ធិពលខ្លាំងក្លាលើរបាយការណ៍ហិរញ្ញវត្ថុបានកើតឡើងក្រោយកាលបរិច្ឆេទនៃតារាងតុល្យការដែលតម្រូវអោយមានការលាតត្រដាងព័ត៌មាន ឬ ធ្វើនិយ័តភាពលើកលែងតែព្រឹត្តិការណ៍ ដូចដែលបានលាតត្រដាងបង្ហាញ នៅក្នុងកំណត់បង្ហាញដែលមានភ្ជាប់ទៅនឹងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

BIDC Be your side, by your hand

## របាយការណ៍របស់គណៈគ្រប់គ្រង

សមាជិកគណៈគ្រប់គ្រង ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ រហូតដល់ថ្ងៃចេញរបាយការណ៍នេះរួមមានៈ

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក Nguyen Van Hien | អគ្គនាយកប្រតិបត្តិ |
| លោកស្រី Mai Thi Ngoc Ha | អគ្គនាយករងជាន់ខ្ពស់ទី១ |
| លោក Pham The Nghiem | អគ្គនាយករង |
| លោក Mey Phy | អគ្គនាយករង |
| លោក Nguyen Danh Thang | អគ្គនាយករង |
| លោក Pham Van Duong | អគ្គនាយករង |

## សវនករ

ក្រុមហ៊ុនសវនករឯករាជ្យ **Ernst & Young** បានសំដែងនូវឆន្ទៈ ដើម្បីទទួលយកការតែងតាំងជាសវនកររបស់ធនាគារ ជាថ្មីម្តងទៀត ។

## ភាគកម្មរបស់គណៈគ្រប់គ្រង

ពុំមានសមាជិកគណៈគ្រប់គ្រងណាម្នាក់កាន់កាប់ ឬ មានការទាក់ទិនផ្ទាល់នៅក្នុងភាគហ៊ុន របស់ធនាគារនៅក្នុង ការិយបរិច្ឆេទនេះទេ ។ ភាគហ៊ុនកាន់កាប់ដោយប្រយោល របស់សមាជិកគណៈគ្រប់គ្រង នៃធនាគារត្រូវបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## អត្ថប្រយោជន៍របស់គណៈគ្រប់គ្រង

នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានការរៀបចំណាមួយដែលមានធនាគារជាគូភាគី ក្នុងគោលបំណងជួយដល់គណៈគ្រប់គ្រងរបស់ធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយនៃការទិញយកភាគហ៊ុន ឬ លិខិតបំណុលពីធនាគារ ឬពីក្រុមហ៊ុនដទៃទៀតទេ ។

*ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទនៃឆ្នាំកន្លងទៅ ពុំមានគណៈគ្រប់គ្រងរបស់ធនាគារណាម្នាក់បានទទួល ឬមានសិទ្ធិទទួល បាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងចំនួនបរិលាភសរុបទទួលបាន ឬប្រាក់ខែថេរកំណត់ទទួលបានដោយគណៈគ្រប់គ្រង ដូចបានបង្ហាញនៅក្នុងកំណត់សំគាល់លេខ ២៤ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈ ការចុះកិច្ចសន្យាធ្វើឡើងដោយធនាគារ ឬដោយក្រុមហ៊ុនពាក់ព័ន្ធមួយ ជាមួយនឹងក្រុមហ៊ុនដែលគណៈគ្រប់គ្រងនោះ ជាសមាជិក ឬក៏ ជាមួយក្រុមហ៊ុនដែលគណៈនាយកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសក្តានុពលមួយនោះទេ ។*

## របាយការណ៍ស្តីពី ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង លើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវដើម្បីធានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុ ពិតជាផ្តល់នូវ ទិដ្ឋភាពពិត និងត្រឹមត្រូវ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ ដល់ និងលទ្ធផលនៃប្រតិបត្តិការ ហើយនិងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទ ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង នាការិយបរិច្ឆេទ ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមគណៈគ្រប់គ្រង ត្រូវបានតម្រូវអោយៈ

- អនុម័តគោលនយោបាយគណនេយ្យសមស្រប ដែលតម្រូវអោយមានការវិនិច្ឆ័យ និង ការប៉ាន់ស្មានដោយសមហេតុផល និងប្រុងប្រយ័ត្ន ហើយនឹងត្រូវអនុវត្តគោលនយោបាយទាំងនោះជាអចិន្ត្រៃយ៍ ។
- អនុវត្តតាមបទបញ្ញត្តិ និងសេចក្តីណែនាំ ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា និង ស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានគំលាតនៃការអនុវត្តចេញពីបទបញ្ញត្តិនិងសេចក្តីណែនាំ ហើយនិងស្តង់ដារដែលជាអត្ថប្រយោជន៏ដល់ការ បង្ហាញនូវភាពពិតនិងត្រឹមត្រូវរបស់របាយការណ៏ហិរញ្ញវត្ថុនោះ គំលាតទាំងនោះត្រូវបានលាតត្រដាងបង្ហាញពន្យល់ និង កំណត់ជាចំនួនទឹកប្រាក់នៅក្នុងរបាយការណ៏ហិរញ្ញវត្ថុ ។
- រក្សាទុកបញ្ជីគណនេយ្យអោយបានគ្រប់គ្រាន់ និង ប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុងអោយមានប្រសិទ្ធភាព ។
- រៀបចំរបាយការណ៏ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីដែល ធនាគារមិនអាចបន្តសកម្មភាពអាជីវកម្មនាពេលអនាគតដែលគិតទុកជាមុនបាន។
- បង្កើតគោលនយោបាយទូទៅសំរាប់ក្រុមហ៊ុនរួមអនុម័តរាល់ការសំរេចចិត្ត និងសកម្មភាពទាំងឡាយរបស់ក្រុម ប្រឹក្សាភិបាលដែលមានឥទ្ធិពលជាសារវ័ន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ ហើយនិង ធានាថាគោលនយោបាយ និង ការសំរេចចិត្តទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងសមស្របក្នុងរបាយការណ៏ហិរញ្ញវត្ថុ ។

ក្រុមគណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវដើម្បីធានាថា បញ្ជីគណនេយ្យត្រឹមត្រូវ ត្រូវបានរក្សាទុក និងលាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ អោយបានត្រឹមត្រូវសមហេតុផលគ្រប់ពេល ហើយនឹងធានាថា បញ្ជីគណនេយ្យស្រប តាមប្រព័ន្ធគណនេយ្យ ដែលបានចុះបញ្ជី ។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សា ទ្រព្យសកម្មរបស់ធនាគារ ហើយម្យ៉ាងទៀតក៏ត្រូវចាត់វិធានការណ៏សមស្របដើម្បីទប់ស្កាត់ និងស្វែងរកកំហុសចេតនា ហើយ និង ភាពមិន ប្រក្រតីផ្សេងៗ។

ក្រុមគណៈគ្រប់គ្រងបញ្ជាក់ថា ធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៏ហិរញ្ញវត្ថុ ។

## ការអនុម័តនៃរបាយការណ៍ហិរញ្ញវត្ថុ

យើងគណៈគ្រប់គ្រងធនាគារ អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់ជាមួយនេះ ផ្តល់នូវទិដ្ឋភាពពិត និងត្រឹម ត្រូវទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារវិនិយោគ និងអភិវឌ្ឍន៏កម្ពុជា ភីអិលស៊ី នាការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ និងលទ្ធផលនៃប្រតិបត្តិការ ហើយនិងលំហូរសាច់ប្រាក់សំរាប់ ការិយបរិច្ឆេទ ដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងបទបញ្ញត្តិ និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ។

តំណាងគណៈគ្រប់គ្រង:

លោក Nguyen Van Hien

អគ្គនាយកប្រតិបត្តិ

ធ្វើនៅរាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០

BIDC Be your side, by your hand

យោង: ៦០៨២៩១៤៨/១៤២១៦៩២៣

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះ : ក្រុមប្រឹក្សាភិបាលនៃធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ **ធនាគារវិនិយោគ និងអភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី** ("ធនាគារ") ដែលពីមុនមានឈ្មោះជាធនាគារវិនិយោគរុងរឿង ភីអិលស៊ី។ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដែលរួមមាន តារាងតុល្យការ នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ របាយការណ៍លទ្ធផល របាយការណ៍ស្តីពីការប្រែប្រួលក្នុងមូលធន សំរាប់កាលបរិច្ឆេទពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ និង របាយការណ៍លំហូរសាច់ប្រាក់ នាកាលបរិច្ឆេទ បញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង គោលនយោបាយគណនេយ្យសំខាន់ៗ និង កំណត់សំគាល់ពន្យល់ផ្សេងទៀត ។ របាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារ សំរាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ និង ឆ្នាំបញ្ចប់ គឺត្រូវបានធ្វើសវនកម្ម ដោយសវនករផ្សេងទៀត ដែលរបាយការណ៍នោះ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ ដោយបញ្ចេញទស្សនៈត្រឹមត្រូវតែលើកលែង លើភាពមិនយល់ស្របទៅលើចំណាត់ថ្នាក់ ឥណទាន និង ប្រាក់បុរេប្រទានអោយទៅ អតិថិជន និង ការមិនអនុលោមទៅតាមកាតព្វកិច្ចប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងធនាគារជាអ្នកទទួលខុសត្រូវចំពោះ ការរៀបចំ និង ការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និង បទបញ្ញត្តិនិងសេចក្តីណែនាំដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។ ការទទួលខុសត្រូវនេះរួមមាន ការរៀបចំ ការអនុវត្ត និង ការរក្សានូវការត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ពន្ធ័ដល់ការរៀបចំ និង ការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្ត័ ដោយកំហុសចេតនា ឬ កំហុសអចេតនា និងការជ្រើសរើស និង ការអនុវត្តន៍គោលនយោបាយគណនេយ្យសមស្រប ហើយនិង ការធ្វើការប៉ាន់ស្មានគណនេយ្យដែលសមស្របទៅ តាមកាលៈទេសៈ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើង គឺ បញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ ។ យើងបានធ្វើការងារ សវនកម្មរបស់យើង ដោយអនុលោមទៅតាមស្តង់ដារសវនកម្មកម្ពុជា និងអន្តរជាតិ ។ ស្តង់ដារទាំងនោះតម្រូវអោយយើង អនុវត្តតាមលក្ខខណ្ឌនៃក្រមសីលធម៌ និងរៀបចំផែនការ និងអនុវត្តការងារសវនកម្មដើម្បីទទួលបាននូវការធានាសមហេតុផល ដើម្បីបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ មិនមានការបង្ហាញភាពមិនត្រឹមត្រូវជាសារវ័ន្តទេ ។

ការងារសវនកម្មយើងរួមមាន ការត្រួតពិនិត្យភស្តុតាងដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់ និង បង្ហាញព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

រាល់នីតិវិធីដែលបានជ្រើសរើសខាងលើ គឺពឹងផ្អែកទៅលើ ការវិនិច្ឆ័យរបស់សវនករដោយរាប់បញ្ចូលនូវការវាយតម្លៃហានិភ័យកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបង្កដោយកំហុសចេតនា ឬ កំហុសអចេតនា។ ក្នុងការវាយតម្លៃលើហានិភ័យទាំងនោះ យើងបានពិនិត្យលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញពីទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ។ ប៉ុន្តែការវាយតម្លៃទាំងនោះមិនមែនសំរាប់គោលបំណងក្នុងការបញ្ចេញមតិយោបល់លើប្រសិទ្ធិភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារនោះទេ ។ ការងារសវនកម្មរបស់យើងក៏រួមបញ្ចូលផងដែរ នូវការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយ គណនេយ្យដែលបានប្រើប្រាស់និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗដែលធ្វើឡើង ដោយអ្នកគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើការបង្ហាញទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ។

យើងជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និង សមស្របដែលផ្តល់នូវមូលដ្ឋាន សំរាប់ការបញ្ចេញមតិយោបល់របស់យើង។

## ទស្សនៈមតិរបស់សវនករ

តាមទស្សនៈមតិរបស់យើង របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវភាពពិត និង ត្រឹមត្រូវ ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាការិយបរិច្ឆេទ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ និង លទ្ធផលនៃប្រតិបត្តិការ ហើយនិងលំហូរសាច់ប្រាក់របស់ធនាគារសំរាប់ការិយបរិច្ឆេទបន្តបន្ទាប់ ឬ ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារ គណនេយ្យកម្ពុជា និងបទបញ្ញត្តិ និងសេចក្តីណែនាំដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ។

ដោយគ្មានការកែប្រែទស្សនៈមតិរបស់យើង យើងសូមទាញអារម្មណ៍ទៅលើកំណត់សំគាល់ លេខ ១ និង ២.២ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ដោយមានការរៀបចំរចនាសម្ព័ន្ធឡើងវិញរបស់ធនាគារ គណៈគ្រប់គ្រងជឿជាក់ថាកាលបរិច្ឆេទ របស់របាយការណ៍នេះបានគ្រប ដណ្តប់លើការិយបរិច្ឆេទមុន និង ក្រោយការរៀបចំរចនាសម្ព័ន្ធឡើងវិញរបស់ធនាគារ ដែលផ្តល់នូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដ៏មានអត្ថន័យមួយ ។ ការិយបរិច្ឆេទនៃរបាយការណ៍នេះ ត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា។

Maria Cristina M. Calimbas
**Ernst & Young Indochina Limited**
ក្រុមហ៊ុនគណនេយ្យករជំនាញ និង សវនកម្មប្រតិស្រុត

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០

Be your side, by your hand

# របាយការណ៍ហិរញ្ញវត្ថុ

## តារាងតុល្យការ

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និង ៣១ ខែ កក្កដា ឆ្នាំ ២០០៩

| | | *នាថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៩* | | *នាថ្ងៃទី៣១ខែកក្កដាឆ្នាំ២០០៩* | |
|---|---|---|---|---|---|
| | *កំណត់សំគាល់* | *ដុល្លារអាមេរិក* | *សមមូល ពាន់រៀល កំណត់សំគាល់ (២.១)* | *ដុល្លារអាមេរិក* | *សមមូល ពាន់រៀល កំណត់សំគាល់ (២.១)* |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៣ | ១៥២.៦៤៣ | ៦៣៦.៣៧០ | ១២០.៧៥៦ | ៥០៦.០៩០ |
| សមតុល្យនៅធនាគារជាតិ | ៤ | ៥២.២៥១.០១៨ | ២១៧.៨៣៤.៤៩៥ | ១.៣៨១.៤៥៨ | ៥.៧៨៩.៦៩០ |
| ប្រាក់បញ្ញើនៅធនាគារនានា | ៥ | ២១.០៧៣.០៥៤ | ៨៧.៨៥៣.៥៦២ | ៤.០៣៦ | ១៦៩១៤ |
| ប្រាក់តំកល់នៅនិងឥណទានផ្តល់ទៅឱ្យធនាគារនានា | ៦ | ១៥.០០៨.០០៤ | ៦២.៥៦៨.៣៦៦ | - | - |
| ឥណទាននិងបុរេប្រទានផ្តល់ទៅឱ្យអតិថិជន | ៧ | ៨៤.២៦៦.០២៨ | ៣៥១.៣០៥.០៧៣ | - | - |
| ទ្រព្យ និង ហត្ថបករណ៍ | ៨ | ៥៣៥.៣៥៦ | ២.២៣១.៨៩៨ | ៤២៨.២៣៣ | ១.៧៩៤.៧២៤ |
| ទ្រព្យអរូបិយ | ៩ | ៣២៩.៣៦១ | ១.៣៧៣.១០៥ | ៣៤៦.៦៣០ | ១.៤៥២.៧២៧ |
| ទ្រព្យផ្សេងៗ | ១០ | ១.០៦១.៥២៧ | ៤.៤២៥.៥០៦ | ២០.០០១ | ៨៣.៨២០ |
| **សរុបទ្រព្យសកម្ម** | | **១៧៤.៦៧៦.៩៩១** | **៧២៨.២២៨.៣៧៥** | **២.៣០១.១១៤** | **៩.៦៤៣.៩៦៦** |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារនានា | ១១ | ៩៣.៥៣២.០៧០ | ៣៨៩.៩៣៥.២០០ | - | - |
| ប្រាក់បញ្ញើរបស់អតិថិជន | ១២ | ១០.៨៩៣.៩៥៧ | ៤៥.៤១៦.៩០៧ | ១៣០.៤៩២ | ៥៤៦.៨៩៣ |
| បំណុលពន្ធ | ១៣ | ២៥.៩៦៧ | ១០៨.២៥៧ | - | - |
| បំណុលនានា | ១៤ | ១០៦.៦១៨ | ៤៤៤.៤៩១ | - | - |
| **សរុបទ្រព្យអកម្ម** | | **១០៤.៥៥៨.៦១២** | **៤៣៥.៩០៤.៨៥៥** | **១៣០.៤៩២** | **៥៤៦.៨៩៣** |
| **មូលធនម្ចាស់ភាគទុនិក** | | | | | |
| មូលធនដែលបានបង់ | ១៥ | ៧០.០០០.០០០ | ២៩១.៨៣០.០០០ | ១៣.៥០០.០០០ | ៥៦.៥៧៨.៥០០ |
| ប្រាក់ចំណេញ(ខាត)ក្នុងគ្រា | ១៥ | ១១៨.៣៧៩ | ៤៩៣.៥២០ | (៤.៣៥៦.២០៦) | (១៨.២៥៦.៨៦២) |
| ការខាតបង់សរុបក្នុងគ្រា | ១៥ | - | - | (៦.៩៧៣.១៧២) | (២៩.២២៤.៥៦៥) |
| **សរុបមូលធនភាគទុនិក** | | **៧០.១១៨.៣៧៩** | **២៩២.៣២៣.៥២០** | **២.១៧០.៦២២** | **៩.០៩៧.០៧៣** |
| **សរុបទ្រព្យអកម្ម និង មូលនិធិភាគទុនិក** | | **១៧៤.៦៧៦.៩៩១** | **៧២៨.២២៨.៣៧៥** | **២.៣០១.១១៤** | **៩.៦៤៣.៩៦៦** |

[*]ដោយមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជាតាមរយៈសេចក្តីជូនដំណឹងលេខធ៧-០៩-៦៥៤ស/ជ/ណ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ នៅមុនពេល IDCC ទិញធនាគារវិនិយោគរុងរឿង ភីអិលស៊ី ទាំងអស់ ជាស្ថាពរធនាគារវិនិយោគ និង អភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី បានលុបចោលរាល់ការខាតបង់ដែលកើតឡើងពីមុនរហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩

ភ្ជាប់ជាមួយកំណត់សំគាល់ពីលេខ ១ ដល់ ២៤ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ

BIDC Be your side, by your hand

# របាយការណ៍លទ្ធផល

សំរាប់កាលបរិច្ឆេទពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩

និងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩

| | *កំណត់សំគាល់* | *ពីថ្ងៃទី១ខែសីហាឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៩* | | *ពីថ្ងៃទី១ខែមករាឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ខែកក្កដាឆ្នាំ២០០៩* | |
|---|---|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល កំណត់សំគាល់ (២.១)* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល កំណត់សំគាល់ (២.១)* |
| ចំណូលការប្រាក់និង ចំណូលប្រហាក់ប្រហែល | ១៦ | ៤៦២.៤០៧ | ១.៩២៧.៧៧៤ | ៨២.៣០៧ | ៣៤៤.៩៥០ |
| ចំណាយការប្រាក់ និង ចំណាយប្រហាក់ប្រហែល | ១៧ | (៩០.១៦៩) | (៣៧៥.៩១៤) | (៥៣៣) | (២.២៣៤) |
| **ការប្រាក់និងចំណូល ប្រហាក់ប្រហែលសុទ្ធ** | | **៣៧២.២៣៨** | **១.៥៥១.៨៦០** | **៨១.៧៧៤** | **៣៤២.៧១៦** |
| ចំណូលបានពីថ្លៃឈ្នួល និងកម្រៃជើងសារ | ១៨ | ២៧៣.១១០ | ១.១៣៨.៥៩៥ | ៣.៦៣៤ | ១៥.២២៨ |
| ចំណាយលើថ្លៃឈ្នួល និងកម្រៃជើងសារ | | (២៤.៦០៨) | (១០២.៥៩០) | (៥១៤) | (២.១៥៥) |
| **ចំណូលបានពីថ្លៃឈ្នួល និងកម្រៃជើងសារសុទ្ធ** | | **២៤៨.៥០២** | **១.០៣៦.០០៦** | **៣.១១៩** | **១៣.០៧៣** |
| ចំណូលបានពីប្រតិបត្តិការនានា | ១៩ | ២៥៨.៨០៦ | ១.០៧៨.៩៦២ | ៤៣១ | ១.៨០៣ |
| **សរុបចំណូលបានពីប្រតិបត្តិការ** | | **៨៧៩.៥៤៦** | **៣.៦៦៦.៨២៧** | **៨៥.៣២៤** | **៣៥៧.៥៩២** |
| ចំណាយរដ្ឋបាលទូទៅ | ២០ | (៧៣១.៥៧៣) | (៣.០៤៩.៩២៧) | (៤៦១.៦៨៦) | (១.៩៣៤.៩២៦) |
| សំវិធានធនលើឥណទាននិងប្រាក់បុរេប្រទាន បាត់បង់ | ៧ | - | - | (៣.៩៧៩.០០០) | (១៦.៦៧៥.៩៨៧) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | | **១៤៧.៩៧៣** | **៦១៦.៩០០** | **(៤.៣៥៥.៣៦១)** | **(១៨.២៥៣.៣២១)** |
| ពន្ធលើប្រាក់ចំណេញ | ១៣ | (២៩.៥៩៤) | (១២៣.៣៨០) | (៨៤៥) | (៣.៥៤០) |
| **ប្រាក់ចំណេញ (ខាត) សុទ្ធក្នុងគ្រា** | | **១១៨.៣៧៩** | **៤៩៣.៥២០** | **(៤.៣៥៦.២០៦)** | **(១៨.២៥៦.៨៦១)** |

ភ្ជាប់ជាមួយកំណត់សំគាល់ពីលេខ ១ ដល់ ២៤ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ

## របាយការណ៍ស្តីពីការប្រែប្រួលក្នុងមូលធន

សំរាប់ការិយបរិច្ឆេទពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩

និងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩

| | *មូលធន* *ដុល្លារអាមេរិក* *កំណត់សំគាល់(១៥)* | *ការកើនឡើងនៃការខាតបង់* *ដុល្លារអាមេរិក* *កំណត់សំគាល់(១៥)* | *សរុប* *ដុល្លារអាមេរិក* |
|---|---|---|---|
| សមតុល្យនាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ | ១៣.៥០០.០០០ | (៦.៩៧៣.១៧២) | ៦.៥២៦.៨២៨ |
| ប្រាក់ចំណេញ(ខាត)សុទ្ធសំរាប់ការិយបរិច្ឆេទ | - | (៤.៣៥៦.២០៦) | (៤.៣៥៦.២០៦) |
| **សមតុល្យនាថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩** | **១៣.៥០០.០០០** | **(១១.៣២៩.៣៧៨)** | **២.១៧០.៦២២** |
| **សមតុល្យនាថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩- សមមូលពាន់រៀលកំណត់សំគាល់ (២.១)** | **៥៦.៥៧៨.៥០០** | **(៤៧.៤៨១.៤២៧)** | **៩.០៩៧.០៧៣** |
| សមតុល្យនាថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ | ១៣.៥០០.០០០ | (១១.៣២៩.៣៧៨) | ២.១៧០.៦២២ |
| វិភាគទានមូលធនក្នុងគ្រា [*] | ៦៧.៨២៩.៣៧៨ | - | ៦៧.៨២៩.៣៧៨ |
| សវិធានធនលើឥណទាន និង បុរេប្រទានបាត់បង់ | (១១.៣២៩.៣៧៨) | ១១.៣២៩.៣៧៨ | - |
| ប្រាក់ចំណេញ (ខាត)សុទ្ធសំរាប់កាលបរិច្ឆេទ | - | ១១៨.៣៧៩ | ១១៨.៣៧៩ |
| **សមតុល្យនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩- ដុល្លារអាមេរិក** | **៧០.០០០.០០០** | **១១៨.៣៧៩** | **៧០.១១៨.៣៧៩** |
| **សមតុល្យនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩- សមមូលពាន់រៀលកំណត់សំគាល់ (២.១)** | **២៩១.៨៣០.០០០** | **៤៩៣.៥២០** | **២៩២.៣២៣.៥២០** |

[*] នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ IDCC បានបញ្ចូលលុយចំនួន ៦៧.៨២៩.៣៧៨ ដុល្លារអាមេរិកដើម្បីបង្កើនទុនរបស់ ធនាគារ វិនិយោគ និង អភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី

[**] ដោយមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជាតាមរយៈសេចក្តីជូនដំណឹង ធ៧-០៩-៦៥៤ស/ជ/ណ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ នៅមុនពេល IDCC ទិញធនាគារវិនិយោគរុងរឿង ភីអិលស៊ី ទាំងអស់ជាស្ថាពរធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី បានលុបចោលរាល់ការខាតបង់ដែលកើតឡើងពីមុនរហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩

## របាយការណ៍លំហូរសាច់ប្រាក់

សំរាប់កាលបរិច្ឆេទពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩

| | *កំណត់សំគាល់* | *៣១ខែធ្នូឆ្នាំ២០០៩* | |
|---|---|---|---|
| | | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | | *(កំណត់សំគាល់២.១)* |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពប្រតិបត្តិការ** | **២១** | **(១.៩៨៨.២៩៣)** | **(៨.២៨៩.១៩៤)** |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | |
| ការទិញ ទ្រព្យ និងបរិក្ខារ | | (១៧៩.៥១០) | (៧៤៨.៣៧៧) |
| ការទិញកម្មវិធីកំព្យូទ័រ | | (៤៦.១១០) | (១៩២.២៣៣) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(២២៥.៦២០)** | **(៩៤០.៦១០)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | |
| វិភាគទានមូលធនក្នុងគ្រា | | ៦៧.៨២៩.៣៧៨ | ២៨២.៧៨០.៦៧៧ |
| **ការប្រែប្រួលសាច់ប្រាក់និងសាច់ប្រាក់សមមូលសុទ្ធ** | | **៦៥.៦១៥.៤៦៥** | **២៧៣.៥៥០.៨៧៣** |
| សាច់ប្រាក់និងសាច់ប្រាក់សមមូលដើមគ្រា | ៣ | ១២៨.៨៥២ | ៥៤០.០១៧ |
| ភាពខុសក្នុងការបំលែងរូបិយប័ណ្ណ | | - | **(២.៨៣៣)** |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលចុងគ្រា** | | **៦៥.៧៤៤.៣១៧** | **២៧៤.០៨៨..០៥៧** |

BIDC Be your side, by your hand

## កំណត់បន្ទាញលើរបាយការណ៍ហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និងថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ និង សំរាប់ការិយបរិច្ឆេទពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩

## ១. ព័ត៌មានអំពីធនាគារ

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី (ធនាគារ) បានចុះបញ្ជីអាជីវកម្មនៅក្នុងព្រះរាជាណាចក្រ កម្ពុជា។

**ការបង្កើតនិងប្រតិបត្តិការ**

ធនាគារវិនិយោគរុងរឿង ភីអិលស៊ី គឺជាសាជីវកម្មធនាគារ ដែលបានចុះបញ្ជីអាជីវកម្មនៅក្នុងព្រះរាជាណាចក្រ កម្ពុជាលេខ ០៧៦៥ កពណ/នកតចុះនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៨ ចេញដោយក្រសួងពាណិជ្ជកម្មនៃ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារវិនិយោគរុងរឿង ភីអិលស៊ី គឺជាធនាគារពាណិជ្ជធ្វើប្រតិបត្តិការស្ថិតក្រោម អាជ្ញាប័ណ្ណលេខ ១៩ ចេញនៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដោយធនាគារជាតិនៃកម្ពុជា។ រាល់សកម្មភាព ប្រតិបត្តិការរបស់ធនាគារ ត្រូវស្ថិតក្រោមច្បាប់ពាណិជ្ជកម្ម និង សហគ្រាសនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំង ស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីអំពីធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនៃ ព្រះរាជាណាចក្រកម្ពុជា ។

នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ ធនាគារវិនិយោគរុងរឿង ភីអិលស៊ី ត្រូវបានទិញដោយក្រុមហ៊ុនវិនិយោគ និងអភិវឌ្ឍន៍ កម្ពុជា “IDCC” ដែលជាមានម្ចាស់ភាគហ៊ុនរួមរវាង ធនាគារវិនិយោគ និង អភិវឌ្ឍន៍ វៀតណាម និង ក្រុមហ៊ុន Phuong Nam (ក្រុមហ៊ុនទាំងពីរជាសញ្ជាតិវៀតណាម) ហើយបានកែទំរង់ និងប្តូរ ឈ្មោះមកជា ធនាគារវិនិយោគ និង អភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី ស្របតាមសេចក្តីសម្រេចលេខ ធ១-០៩-៥៥៤ របស់អគ្គទេសា ភិបាលនៃធនាគារជាតិនៃកម្ពុជា ចុះនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ និងមានសុពលភាពចាប់ពី ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ តទៅ។

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី គឺជាគ្រឹះស្ថានហិរញ្ញវត្ថុមួយដែលប្រតិបត្តិការស្របតាមច្បាប់ និង បទបញ្ជារបស់ធនាគារជាតិនៃកម្ពុជា ។ ធនាគារប្រតិបត្តិដោយមានការគាំទ្រដោយផ្ទាល់ពី ធនាគារវិនិយោគ និង អភិវឌ្ឍន៍វៀតណាម ដែលជាធនាគារដ៏ធំមួយនៅក្នុងប្រទេសវៀតណាម ដែលបានផ្តល់សេវាកម្មផ្នែក ធនាគារ ច្រើនជាង ៥០ ឆ្នាំមកហើយ ។ ធនាគារវិនិយោគ និង អភិវឌ្ឍន៍ វៀតណាម ជួយគាំទ្រ ធនាគារ វិនិយោគ និង អភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី ក្នុងការអភិវឌ្ឍន៍ និង ធ្វើឱ្យប្រសើរឡើងផ្នែកប្រព័ន្ធបច្ចេកវិទ្យាប្រព័ន្ធ និង វិធីសាស្ត្រទាំងឡាយ ព្រមទាំង ការផ្តល់នូវ ផលិតផល និង សេវាកម្មធនាគារ ដែលមានគុណភាពខ្ពស់។

សកម្មភាពចំបងរបស់ធនាគារ គឺការផ្តល់នូវសេវាកម្មផ្នែកធនាគារ និង ហិរញ្ញវត្ថុដ៏ទូលំទូលាយក្នុងប្រទេសកម្ពុជា និង វៀតណាម។

**មូលធន**

គិតមកត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ធនាគារមានមូលធនជាក់ស្តែងចំនួន ៧0.000.000 ដុល្លារអាមេរិក (ចិតសិបលានដុល្លារអាមេរិក) ។

**ក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ រហូតដល់ថ្ងៃចេញរបាយការណ៍នេះរួមមាន:

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក Tran Thanh Van | ប្រធាន |
| លោក Nguyen Tien Bac | អនុប្រធាន |
| លោក Nguyen Van Hien | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក Pham Van Duong | សមាជិកក្រុមប្រឹក្សាភិបាល |
| លោកស្រី Le Thanh Van | សមាជិកក្រុមប្រឹក្សាភិបាល |
| លោក Tran Dinh Dinh | សមាជិកក្រុមប្រឹក្សាភិបាល |
| លោកស្រី Tran Thi Oanh | សមាជិកក្រុមប្រឹក្សាភិបាល |

សមាជិកក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ រហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ នេះ រួមមាន:

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក Nguyen Thien Nhan | ប្រធាន |
| លោក Mey Phy | អនុប្រធាន |
| លោកស្រី Nguyen Thanh Thuy | សមាជិកក្រុមប្រឹក្សាភិបាល |

**គណៈគ្រប់គ្រង**

សមាជិកក្រុមប្រតិបត្តិចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ រហូតដល់ថ្ងៃចេញរបាយការណ៍នេះរួមមាន:

| *ឈ្មោះ* | *មុខងារ* |
|---|---|
| លោក Nguyen Van Hien | អគ្គនាយកប្រតិបត្តិ |
| លោកស្រី Mai Thi Ngoc Ha | អគ្គនាយករងជាន់ខ្ពស់ទី១ |
| លោក Pham The Nghiem | អគ្គនាយករង |
| លោក Mey Phy | អគ្គនាយករង |
| លោក Nguyen Danh Thang | អគ្គនាយករង |
| លោក Pham Van Duong | អគ្គនាយករង |

**អាសយដ្ឋាន**

ទីស្នាក់ការកណ្តាលរបស់ធនាគារ មានអាសយដ្ឋាននៅអាគារលេខ ២៣ ផ្លូវក្រមួនសរ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ ធនាគារមានសាខាមួយកន្លែង នៅទីក្រុងហូជីមិញ ប្រទេស វៀតណាម ។

**បុគ្គលិក**

ធនាគារមានបុគ្គលិកសរុបចំនួន ៤៥ នាក់បំរើការនៅទីស្នាក់ការកណ្តាលរាជធានីភ្នំពេញនិង ៤២ បំរើការនៅសាខាមួយទីក្រុងហូជីមិញគិតមកត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ។

## ២. គោលនយោបាយគណនេយ្យ

### ២.១. មូលដ្ឋាននៃការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

ធនាគាររៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនតាមវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រ ។ ធនាគាររក្សាទុកការកត់ត្រាបញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ របស់ខ្លួនជារូបិយប័ណ្ណដុល្លារអាមេរិក តាមប្រកាសលេខធ៧-០៧-១៦៤ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧ ។

របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយ រួមទាំងការប្រើប្រាស់របាយការណ៍នេះ មិនត្រូវបានរៀបចំឡើងសំរាប់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដែលពុំបានដឹងពីគោលការណ៍គណនេយ្យ នីតិវិធីគណនេយ្យ និងការអនុវត្តគោលនយោបាយគណនេយ្យនៃព្រះរាជាណាចក្រកម្ពុជា ហើយនិងមិនមានបំណងក្នុងការបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ និង លទ្ធផលអាជីវកម្ម និងលំហូរសាច់ប្រាក់ដែលអនុលោមទៅតាមគោលការណ៍គណនេយ្យ និងការអនុវត្តគណនេយ្យ ដែលទទួលស្គាល់ជាទូទៅក្នុងប្រទេសដ៏ទៃក្រៅពីព្រះរាជាណាចក្រកម្ពុជាទេ ។

ការប្រែសំរួលទឹកប្រាក់ពីរូបិយប័ណ្ណដុល្លារអាមេរិកមកជាខ្មែររៀល("ពាន់រៀល") ត្រូវបានបង្ហាញក្នុងរបាយការណ៍ ហិរញ្ញវត្ថុដោយអនុលោមទៅតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និង វិជ្ជាជីវៈ គណនេយ្យចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០២ និងប្រកាសពាក់ព័ន្ធនានារបស់ធនាគារជាតិនៃកម្ពុជា ដោយប្រើអត្រា ប្តូរប្រាក់ជាមធ្យម ៤.១៦៩រៀល ក្នុង ១ដុល្លារអាមេរិកនាកាលបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ (ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩: ៤.១៩១រៀល ក្នុង ១ដុល្លារអាមេរិក និង ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩: ៤.០៨១រៀល ក្នុង ១ដុល្លារអាមេរិក) ដូចដែលបានប្រកាសឱ្យប្រើដោយធនាគារជាតិនៃកម្ពុជា ។ ការប្រែសំរួលនេះមិនគួរត្រូវបាន យកមកធ្វើការបកស្រាយបង្ហាញថា ចំនួនទឹកប្រាក់ជារូបិយប័ណ្ណដុល្លារអាមេរិក ត្រូវបានប្តូរទៅជារូបិយប័ណ្ណ ខ្មែររៀលវិញនៅក្នុងអត្រានេះ ឬ ក្នុងអត្រាប្តូរប្រាក់ដទៃទៀតឡើយ ។ របាយការណ៍ស្តីពីលំហូរសាច់ប្រាក់ ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ មិនត្រូវបានរៀបចំទេ ដោយសារព័ត៌មានដែលទទួលបាន ពីប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ធនាគារមានកម្រិត មុនពេលធនាគារត្រូវបានទិញដោយ IDCC ។ ក្នុងកំឡុងពេលនេះ ធនាគារបានប្រើប្រាស់យ៉ាងជាក់លាក់នូវគោលនយោបាយគណនេយ្យខាងក្រោម ។

## ២.២. ឆ្នាំសារពើពន្ធនិងរយៈពេលនៃការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

ឆ្នាំសារពើពន្ធរបស់ធនាគារគឺចាប់ផ្តើមពីថ្ងៃទី ១ ខែ មករា ឆ្នាំ និងបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ។

តាមការរៀបចំឡើងវិញ (សូមមើលកំណត់សំគាល់លេខ ១) ធនាគារបានបង្កើតឡើងតាម អាជ្ញាប័ណ្ណថ្មីចេញដោយ ក្រសួងពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណថ្មីមួយ ទៀតចេញដោយ ធនាគារជាតិនៃកម្ពុជា ។BIDC ក៏បានបង្កើត ក្រុមប្រឹក្សាភិបាលថ្មី និងគណៈគ្រប់គ្រង ។ តាមការរៀបចំឡើងវិញនេះ គណៈគ្រប់គ្រងជឿជាក់ថា ការិយបរិច្ឆេទហិរញ្ញវត្ថុផ្សេងគ្នាទាំងពីរនេះ សំរាប់ឆ្នាំ ២០០៩ ដែលរាយនាមជាការិយបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ និងសំរាប់ការិយបរិច្ឆេទ ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ក្រោយ ការរៀបចំរចនាសម្ពន្ធ័ឡើងវិញរបស់ធនាគារ និងនាកាលបរិច្ឆេទថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៩ មុនការរៀបចំ រចនាសម្ពន្ធ័ ឡើងវិញរបស់ធនាគារ ប៉ុន្តែមិនមានការប្រៀបធៀប ដែលផ្តល់នូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារដ៏មានអត្ថន័យមួយ ដោយសារតែការិយបរិច្ឆេទហិរញ្ញវត្ថុគ្របដណ្តប់ការិយបរិច្ឆេទបន្ទាប់ពីធនាគារត្រូវបាន ទិញដោយ IDCC និងការិយបរិច្ឆេទមុនការទិញ ។ ការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដើម្បីគ្របដណ្តប់ លើការិយបរិច្ឆេទហិរញ្ញវត្ថុ ត្រូវបានអនុម័ត ដោយធនាគារជាតិនៃកម្ពុជា ដោយយោងតាមលិខិតប្រកាសលេខ ធ៧/១០/៦៩ ចុះ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០ ។

## ២.៣. ការវិនិច្ឆ័យនិងការប៉ាន់ស្មានគណនេយ្យសំខាន់ៗ

ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ធនាគារអ្នកគ្រប់គ្រងបានប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន និង ធ្វើការ ប៉ាន់ស្មានក្នុងការកំណត់បរិមាណដែលត្រូវបានទទួលស្គាល់ក្នុង របាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម:

### ២.៣.១. ការខាតបង់ដោយការថយតម្លៃរបស់ឥណទាន និង ប្រាក់បុរេប្រទានអោយអតិថិជន

នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គុណភាពនៃឥណទាន និង ប្រាក់បុរេប្រទានអោយអតិថិជនត្រូវបាន ត្រួតពិនិត្យ និងវាយតម្លៃដើម្បីកំណត់ចំណាត់ថ្នាក់និងកំរិត នៃសំវិធានធនលើការខាតបង់ដោយការថយចុះតម្លៃ ដែលបានបង្ហាញនៅក្នុងកំណត់សំគាល់លេខ ២.៤.៤ ។

## ២.៤. សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ

### ២.៤.១. ព័ត៌មានវិយោគកម្ម

ធនាគារ ធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនស្ថិតនៅក្នុងដែនភូមិសាស្ត្រតែពីរ គឺព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ។

ព័ត៌មានវិយោគកម្មត្រូវបានបង្ហាញ តាមផ្នែកនៃអាជីវកម្មរបស់ធនាគារ ។ ចំនែកឯរបៀបជាចំបងក្នុងការ រៀបចំព័ត៌មានអាជីវកម្មតាមផ្នែកត្រូវបានធ្វើឡើងដោយផ្អែកទៅលើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលត្រូវបាន ប្រើប្រាស់ដោយអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ក្នុងការធ្វើសេចក្តីសំរេចចិត្ត និង ការអនុវត្តការគ្រប់គ្រង ។

ប្រតិបត្តិការរវាងផ្នែកនីមួយៗត្រូវបានកត់ត្រាដាច់ដោយឡែកទៅតាមផ្នែកនីមួយៗ ទោះបីជាប្រតិបត្តិការទាំងនោះជាប្រតិបត្តិការភាគីតតិយជនក៏ដោយ និងត្រូវបានលុបបំបាត់ចោលនៅពេលធ្វើរបាយការណ៍រួម ។ រាល់ប្រតិបត្តិការរវាងផ្នែកនីមួយៗ ត្រូវបានរៀបចំឡើង តាមមូលដ្ឋានប្រតិបត្តិការជាធម្មតារបស់ធនាគារ ដែលមិនអាចច្រើនជាងការផ្តល់សេវាជាទូទៅដល់សាធារណៈឡើយ ។

លទ្ធផលនៃព័តិមាន ជាផ្នែកនៃទ្រព្យសកម្ម និង ទ្រព្យអកម្ម រួមមានចំនួនធាតុទាំងឡាយ ដែលរួមចំនែកដោយផ្ទាល់ទៅផ្នែកនៃអាជីវកម្មនោះ ព្រមទាំងធាតុទាំងឡាយណាដែលអាចបែងចែក ផ្អែកលើមូលដ្ឋានយ៉ាងសមហេតុផល ។

### ២.៤.២. សាច់ប្រាក់ និង សាច់ប្រាក់ប្រហាក់ប្រហែល

សំរាប់គោលបំណងរបាយការណ៍លំហូរសាច់ប្រាក់សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ និង ការវិនិយោគរយៈពេលខ្លីដែលអាចប្តូរជាសាច់ប្រាក់បានក្នុងរយៈកាលអវសានដើម ៣០ថ្ងៃ ដែលអាចប្តូរបាននូវ សាច់ប្រាក់ និងគណនេយ្យហួសកាលកំណត់ពីធនាគារក្នុងរយៈកាលអវសានដើមតិចជាង៩០ថ្ងៃ ។

### ២.៤.៣ ឥណទាន និង ប្រាក់បុរេប្រទាន

រាល់ប្រាក់អោយខ្ចី និងប្រាក់បុរេប្រទានអោយអតិថិជន ត្រូវបានបង្ហាញក្នុងតារាងតុល្យការ ជាទឹកប្រាក់ដើម និងការប្រាក់បង្គរ ដែលមិនទាន់ត្រូវបានទូទាត់ ដកឥណទានដែលត្រូវបានលុបចោល និងសំវិធានធនចំពោះ ឥណទានបាត់បង់ ។ ឥណទានរយៈពេលខ្លី គឺជាឥណទានដែលនឹងត្រូវទូទាត់សងមកវិញ នៅក្នុងរយៈពេលមួយឆ្នាំ ដោយគិតពីកាលបរិច្ឆេទដែលឥណទានត្រូវបានផ្តល់អោយអតិថិជន ។ ឥណទានរយៈពេលវែង គឺជាឥណទាន ដែលនឹងត្រូវទូទាត់សងមកវិញនៅក្នុងរយៈពេលច្រើនជាងមួយឆ្នាំ ដោយគិតពីកាលបរិច្ឆេទដែលប្រាក់អោយខ្ចី ចងការ ត្រូវបានផ្តល់អោយ ។

ឥណទាន ត្រូវបានលុបចោល នៅពេលដែលធនាគារមិនសង្ឃឹមច្បាស់លាស់ថា ឥណទានអាចប្រមូលមកវិញបាន ។ ការប្រមូលបានមកវិញនៃឥណទាន និង ប្រាក់បុរេប្រទាន ដែលត្រូវបានលុបចោល នៅក្នុងការិយបរិច្ឆេទមុនៗ នឹងបន្ថយទឹកប្រាក់នៃសំវិធានធនសំរាប់ឥណទានបាត់បង់ និង ការថយចុះតំលៃនៃឥណទាន និងប្រាក់បុរេប្រទាននៅក្នុងរបាយការណ៍លទ្ធផល ។

ឥណទានដែលត្រូវបានចាត់ថ្នាក់ជា ក្រោមស្តង់ដារ សង្ស័យ ឬ បាត់បង់ គឺត្រូវចាត់ទុកជាឥណទានមិនដំណើរការ ។

### ២.៤.៤ សំវិធានធនលើឥណទាន និង ប្រាក់បុរេប្រទានបាត់បង់

សំវិធានធនលើឥណទាន និងប្រាក់បុរេប្រទានបាត់បង់ ត្រូវបានធ្វើឡើងអាស្រ័យទៅលើហានិភ័យជាក់លាក់នានាដែលទាក់ទងទៅនឹងឥណទាន និងបុរេប្រទានទាំងនោះដែលបានពិនិត្យមើល និង កំណត់យ៉ាងជាក់លាក់ថាជាឥណទានឃ្លាំមើល ក្រោមស្តង់ដារ ជាប់សង្ស័យ ឬបាត់បង់។ ការធ្វើសំវិធានធន គឺត្រូវបានគណនាដោយផ្អែកទៅលើភាគរយនៃឥណទាន និងប្រាក់បុរេប្រទានសរុប (ដោយរួមបញ្ចូលទាំងការប្រាក់បង្គរ) ដកចេញការប្រាក់ ព្យួរទុក។

ធនាគារបានអនុវត្តតាមការកំណត់អំពីចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ដែលតម្រូវដោយធនាគារជាតិនៃ កម្ពុជា តាមប្រកាសលេខ ធ៧-០៩-០៧៤ ចុះថ្ងៃទី ២៥ កុម្ភៈ ២០០៩ ។ ប្រកាសនេះតម្រូវអោយធនាគារ ពាណិជ្ជទាំងអស់ធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជា ៥ ថ្នាក់។ កំរិតអប្បបរមាចាំបាច់នៃការធ្វើសំវិធានធនទូទៅ និង ជាក់លាក់ត្រូវបានធ្វើឡើងដោយផ្អែកលើ ការធ្វើចំណាត់ថ្នាក់ឥណទាន ដូចខាងក្រោម:

| *ចំណាត់ថ្នាក់* | *ចំនួនថ្ងៃដែលហួសកាលកំណត់សង* | *សំវិធានធន* |
|---|---|---|
| ឥណទានធម្មតា | ពី០ថ្ងៃទៅ៣០ថ្ងៃ | ១% |
| ឥណទានឃ្លាំមើល | ពី៣០ថ្ងៃទៅ៩០ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ពី៩០ថ្ងៃទៅ១៨០ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ពី១៨០ថ្ងៃទៅ៣៦០ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | លើសពី៣៦០ថ្ងៃ | ១០០% |

ឥណទានដែលមិនអាចទារបាន ឬចំណែកនៃឥណទានដែលបានចាត់ថ្នាក់ជាបំណុលអាក្រក់ ត្រូវបានកាត់ចេញ បន្ទាប់ពីមានការគិតគូរទៅលើតម្លៃលក់បាននៃទ្រព្យបញ្ចាំ (ប្រសិនបើមាន) នៅពេលដែលអ្នកគ្រប់គ្រងវិនិច្ឆ័យឃើញថា ពុំមានសង្ឃឹមនឹងទារបាននូវឥណទានទាំងនោះមកវិញទេ ។

### ២.៤.៥ *ការសន្យានៃឥណទានផ្សេងៗ*

នៅក្នុងអាជីវកម្មធម្មតា ធនាគារ មានការសន្យានៃឥណទានផ្សេងៗ ដែលរួមមាន ការសន្យាផ្តល់ប្រាក់កម្ចី លិខិត ឥណទាន និង លិខិតធានា ។ គោលនយោបាយគណនេយ្យ និង វិធីសាស្ត្រសំវិធានធន គឺមាន លក្ខណៈដូចទៅនឹង ឥណទានដែលបានផ្តល់អោយដំបូង ដូចដែលកំណត់បង្ហាញខាងលើ ។ សំវិធានធនលើការសន្យានៃឥណទាន ផ្សេងៗ ត្រូវបានធ្វើឡើងនៅពេលការបាត់បង់ ត្រូវបានគិតថា ទំនងនឹងកើតមានឡើង ។

### ២.៤.៦ **ប្រាក់បញ្ញើ និង ប្រាក់ដំកល់ជាមួយធនាគារ**

ប្រាក់បញ្ញើនិងប្រាក់ដំកល់ជាមួយធនាគារគឺត្រូវប្រតិបត្តិក្នុងថ្លៃដើម ។

### ២.៤.៧ *ទ្រព្យសកម្មផ្សេងៗ*

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាទៅតាមតម្លៃដែលរំពឹងទុកថាប្រមូលបាន ។ ការប៉ាន់ស្មានត្រូវធ្វើឡើងសំរាប់បំណុលជាប់សង្ស័យ ដោយផ្អែកលើការពិនិត្យសារឡើងវិញចំពោះបរិមាណនៅសល់ នាកាលបរិច្ឆេទតារាង តុល្យការ ។

### ២.៤.៨ ប្រាក់បញ្ញើតាមច្បាប់

ប្រាក់បញ្ញើតាមច្បាប់ សំរាប់សកម្មភាពទាក់ទងទៅនឹងធនាគារ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃ ដើមទុនអប្បបរមារបស់ ធនាគារ និង ប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

### ២.៤.៩ ទ្រព្យអរូបិយ

ទ្រព្យអរូបិយ ត្រូវបានកត់ត្រាតាមតម្លៃដើមដកនូវរំលស់បង្គរ ។ ទ្រព្យអរូបិយ ត្រូវបានដករំលស់ ដោយប្រើមូលដ្ឋានរំលស់ថេរតាមអត្រា ២៥%ក្នុងមួយឆ្នាំ ។

### ២.៤.១០ ទ្រព្យ និងបរិក្ខារ

(ក) ទ្រព្យ និងហត្ថូបករណ៍ ត្រូវបានកត់ត្រាតាមតម្លៃដើមដោយដករំលស់បង្គរ និងការខាតបង់នៃឱនភាព តម្លៃបង្គរ ប្រសិនបើមាន ។ នៅពេលដែលធាតុនៃទ្រព្យសម្បត្តិរួមបញ្ចូលនូវសមាសធាតុសំខាន់ៗ ដែលមាន អាយុកាលកំណត់ ប្រើប្រាស់ខុសៗគ្នា អចលនទ្រព្យទាំងនោះត្រូវបានចាត់ទុកជាធាតុផ្សេងគ្នានៃ ទ្រព្យ និងហត្ថូបករណ៍ ។

(ខ) ដី និងការសាងសង់កំពុងដំណើរការមិនត្រូវបានធ្វើរំលស់ទេ ។ រំលស់លើអចលនទ្រព្យ និងទ្រព្យសំភារៈ លើកលែងតែអគារចេញ ត្រូវបានចាត់ជាចំណាយទៅក្នុង របាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋាន រំលស់ថេរ ទៅលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់អចលនទ្រព្យនីមួយៗដែលមានអត្រា រំលស់ប្រចាំឆ្នាំ ដូចខាងក្រោម:

| | |
|---|---|
| ការជួសជុលកែលំអអាគារ | ៣% |
| សំភារៈការិយាល័យ | ២៥% |
| សំភារៈបច្ចេកវិទ្យាព័ត៌មាន | ២៥% |
| រថយន្ត | ២៥% |
| កម្មវិធីកុំព្យូទ័រ | ២៥% |
| ទ្រព្យអរូបិយផ្សេងៗ | ២៥% |

(គ) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងហត្ថូបករណ៍ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានរួមបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម នៅពេលដែលអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគត ដែល នឹងកើតមានបានបញ្ចូលទៅក្នុងធនាគារនៅក្នុងលក្ខខណ្ឌលើស ពីថ្លៃដើមស្តង់ដារ នៃទ្រព្យសកម្មដែល កំពុងមាននោះ ។ រាល់ការចំណាយបន្ទាប់ផ្សេងទៀតត្រូវបានទទួល ស្គាល់ជាបន្ទុក ចំណាយនៅក្នុង ការិយបរិច្ឆេទ ដែលបានកើតឡើង ។

(ឃ) ដី និង ការសាងសង់កំពុងដំណើរការ ត្រូវបានកត់ត្រាតាមតម្លៃដើម ។ តម្លៃនៃការសាងសង់នេះរួមបញ្ចូលថ្លៃដើមនៃការសាងសង់ ទ្រព្យសំភារៈ និង ថ្លៃដើមផ្ទាល់ផ្សេងៗទៀត ។ ការសាងសង់កំពុងដំណើរការ មិនត្រូវបានគិតរំលស់ទេ រហូតទាល់តែការសាងសង់នេះបានបញ្ចប់ ហើយទ្រព្យ និងហត្ថូបករណ៍ដែលពាក់ព័ន្ធ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងប្រតិបត្តិការអាជីវកម្ម ។

(ង) ចំណេញ ឬខាតពីការបោះចោល ឬការលក់ចេញនៃទ្រព្យ និងហត្ថបករណ៍ណាមួយត្រូវបាន កំណត់ដោយភាពខុសគ្នារវាង ប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងនៃទ្រព្យសម្បត្តិនោះ ហើយត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលនៅថ្ងៃបោះចោល ឬ លក់ចេញ ។

(ច) ទ្រព្យ និងហត្ថបករណ៍ ដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុ រហូតដល់ ថ្ងៃដែលអចលនទ្រព្យ និង ទ្រព្យសំភារៈទាំងនោះត្រូវបានលក់ ឬ លុបបំបាត់ចោល ។

(ឆ) តម្លៃយោងនៃទ្រព្យ និងហត្ថបករណ៍ ត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញចំពោះឱនភាពនៃតម្លៃ នៅពេល ដែលមានការគូសបញ្ជាក់ណាមួយឱ្យដឹងថា ទ្រព្យសកម្មនោះចាំបាច់ត្រូវបន្ថយតម្លៃ ។ តម្លៃបាត់បង់ ត្រូវបានវាស់វែង ដោយប្រៀបធៀបតម្លៃយោងរបស់ទ្រព្យសកម្មជាមួយតម្លៃដែលអាចប្រមូលបានវិញ ។ ការខាតបង់ លើការថយចុះនៃតម្លៃត្រូវបានចាត់ចូលជាបន្ទុកក្នុងរបាយការណ៍លទ្ធផល ។

ការដាក់បញ្ចូលមកវិញនូវការខាតបង់លើឱនភាពនៃតម្លៃដែលបានទទួលស្គាល់ពីឆ្នាំមុនៗ ត្រូវបានកត់ត្រាឡើងវិញនៅពេលដែលមានការគូសបញ្ជាក់អោយដឹងថា ការខូចបង់លើឱនភាពនៃតម្លៃដែលបានទទួល ស្គាល់សំរាប់ទ្រព្យសកម្មនោះលែងកើតមានទៀត ឬ ត្រូវបានថយចុះហើយ។ ការដាក់បញ្ចូលមកវិញនេះ ត្រូវបានទទួលស្គាល់ត្រឹមកំរិតតម្លៃយោងនៃទ្រព្យសកម្មដែលត្រូវបានកំណត់ (តម្លៃសុទ្ធបន្ទាប់ពីដក រំលស់) ប្រសិនបើពុំមានការខាតបង់លើឱនភាពនៃតម្លៃទេនោះ ។ ការដាក់បញ្ចូលមកវិញនេះ ត្រូវបានទទួលស្គាល់ ក្នុងរបាយការណ៍លទ្ធផលផងដែរ ។

### ២.៤.១១ បំណុល

ប្រាក់បញ្ញើពីអតិថិជន ប្រាក់បញ្ញើ និងប្រាក់តំកល់នៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុនានា ត្រូវបានបង្ហាញក្នុងតម្លៃដែលបានដាក់តំកល់។ បំណុលផ្សេងទៀតត្រូវបានបង្ហាញក្នុងតម្លៃដើម ដែលជាតម្លៃគិតពិចារណាបច្ចុប្បន្ន ដែលរំពឹងបង់នាពេលអនាគត ចំពោះទំនិញឬ សេវាកម្មដែលបានទទួល។

សំវិធានធនលើបំណុល ត្រូវបានទទួលស្គាល់នៅពេលដែលធនាគារ មានកាតព្វកិច្ចតាមផ្លូវច្បាប់បច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ ពីអតីតកាល ហើយវាទំនងជាមានលទ្ធភាព ដែលតម្រូវអោយមានលំហូរចេញផលប្រយោជន៏សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ហើយការប៉ាន់ស្មាននៃបរិមាណ នោះត្រូវបានធ្វើឡើង។

សំវិធានធនត្រូវបានត្រួតពិនិត្យឡើងវិញនាកាលបរិច្ឆេទនីមួយៗនៃតារាងតុល្យការ ហើយធ្វើការកែតម្រូវ អោយស្របទៅនឹងការប៉ាន់ស្មានល្អបំផុតនាពេលបច្ចុប្បន្ន ។ នៅពេលតម្លៃពេលវេលានៃសាច់ប្រាក់មានឥទ្ធិពលជាសារវ័ន្ត បរិមាណសំវិធានធន គឺជាតម្លៃបច្ចុប្បន្ននៃការចំណាយដែលរំពឹងទុកដើម្បីទូទាត់បំណុល។

### ២.៤.១៣ ពន្ធលើប្រាក់ចំណេញ

**ពន្ធក្នុងគ្រា**

ពន្ធក្នុងគ្រាលើទ្រព្យសកម្ម និង ទ្រព្យអកម្ម សំរាប់ការិយបរិច្ឆេទបច្ចុប្បន្ន និងមុនៗ ត្រូវបានវាស់វែងជា ទឹកប្រាក់ ដែលត្រូវបានរំពឹងទុកថា ត្រូវបានប្រមូលមកវិញពី ឬត្រូវបង់អោយអាជ្ញាធរពន្ធដារ ។ អត្រាពន្ធ និងច្បាប់ពន្ធ ដែលត្រូវបានប្រើដើម្បីគណនាទឹកប្រាក់ទាំងនេះ គឺជាអត្រា និងច្បាប់ពន្ធ ដែលមានសុពលភាពរហូតដល់ កាលបរិច្ឆេទនៃតារាងតុល្យការ ។

**ពន្ធពន្យារ**

ពន្ធពន្យារត្រូវបានគណនា ដោយប្រើវិធីសាស្រ្តបំណុលតុល្យការ លើចំនួនខុសគ្នាបណ្តោះអាសន្ន នាកាល បរិច្ឆេទនៃតារាងតុល្យការ រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល ហើយនិងតម្លៃពិតគណនេយ្យរបស់ពួកវាក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ពន្ធពន្យារលើទ្រព្យអកម្ម ត្រូវបានទទួលស្គាល់លើ ចំនួនខុសគ្នាបណ្តោះអាសន្នជាប់ពន្ធទាំងអស់ លើកលែងតែ នៅពេលពន្ធពន្យារលើទ្រព្យអកម្ម កើតឡើងពីការទទួលស្គាល់នៅគ្រាដំបូងនៃទ្រព្យសកម្ម ឬ បំណុល នៅក្នុងប្រតិបត្តិការដែលនៅពេលនោះ វាមិនជះឥទ្ធិពលដល់ប្រាក់ចំណេញតាមវិធីសាស្រ្ត គណនេយ្យ និង ប្រាក់ចំណេញ ឬខាត ជាប់ពន្ធ ។

ពន្ធន្យារលើទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ សំរាប់ភាពខុសគ្នាបណ្តោះអាសន្នទាំងអស់ ដែលអាចកាត់បន្ថយ បានរហូតដល់ទំហំមួយ ដែលវាទំនងថា ប្រាក់ចំណេញជាប់ពន្ធ នឹងអាចមានដើម្បីកាត់កងជាមួយភាពខុសគ្នាបណ្តោះអាសន្ន ដែលអាចប្រើប្រាស់បាន លើកលែងតែនៅពេលពន្ធពន្យារលើទ្រព្យសកម្ម កើតឡើងពីការ ទទួលស្គាល់នាគ្រាដំបូងនៃទ្រព្យសកម្ម ឬបំណុលក្នុងប្រតិបត្តិការ ដែលនៅពេលប្រតិបត្តិការនោះ មិនមាន ឥទ្ធិពលដល់ប្រាក់ចំណេញតាមវិធីសាស្រ្តគណនេយ្យ និងប្រាក់ចំណេញ ឬខាតជាប់ពន្ធ ។

Be your side, by your hand

តម្លៃពិតគណនេយ្យនៃពន្ធពន្យារលើទ្រព្យសកម្ម ត្រូវបានពិនិត្យឡើងវិញនាកាលបរិច្ឆេទតុល្យការនីមួយៗ ហើយនិងត្រូវបានកាត់បន្ថយមកត្រឹមទំហំមួយ ដែលវាមិនទំនងថាមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់នឹង អាចផ្តល់អោយទ្រព្យសកម្មទាំងអស់ ឬមួយផ្នែកអាចស្តារមកវិញនាពេលអនាគត ។ ពន្ធលើប្រាក់ចំណូល ពន្យារលើទ្រព្យសកម្មដែលមិនត្រូវបានទទួលស្គាល់នោះ គឺត្រូវបានវាយតម្លៃឡើងវិញ នាកាលបរិច្ឆេទនៃតុល្យការនីមួយៗ ហើយត្រូវបានទទួលស្គាល់នូវតែទំហំមួយដែលវាទំនងថា ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត នឹងធ្វើអោយពន្ធពន្យារលើទ្រព្យសកម្មនោះ អាចត្រូវបានយកត្រលប់មកវិញ ។

### ២.៤.១៤ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានកាត់កងគ្នា ហើយចំនួនទឹកប្រាក់សុទ្ធ ត្រូវបានបង្ហាញក្នុងតារាងតុល្យការតែក្នុងករណីដែលមានសិទ្ធិស្របច្បាប់ ដើម្បីកាត់កងទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ ហើយមានបំណងទូទាត់តាមមូលដ្ឋានសុទ្ធ ឬលក់ទ្រព្យសកម្ម និងទូទាត់បំណុលនៅពេលទន្ទឹមគ្នានោះ ។ ជាទូទៅនេះ មិនមែនជា

ករណើរបស់កិច្ចព្រមព្រៀងកាត់កងឡើយ ហើយទ្រព្យសកម្ម និង ក្រុមហ៊ុនបំណុលពាក់ព័ន្ធ ត្រូវបាន បង្ហាញជាទឹកប្រាក់ដុលក្នុងតារាងតុល្យការ ។

### ២.៤.១៥ ការទទួលស្គាល់ចំណូល និង ចំណាយ

*(ក) ចំណូលពីការប្រាក់*

ចំណូលពីការប្រាក់ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ ។ ចំណូលពីការប្រាក់ លើឥណទាន វិបារូបន៍ ឥណទានមានកាលកំណត់ និងឥណទានផ្សេងទៀតត្រូវបាន ទទួលស្គាល់ដោយយោងទៅតាម ពេលវេលាដែលគិតប្រចាំខែ ឬប្រចាំថ្ងៃ ។ នៅពេលឥណទានមួយក្លាយជាមិនដំណើរការ ការប្រាក់ត្រូវបាន ព្យួរទុក បើពុំនោះទេ លុះត្រាតែត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានសាច់ប្រាក់ ។ ឥណទានអតិថិជនទាំងនោះ ត្រូវបានចាត់ទុកជាគណនីមិនដំណើរការនៅពេលដែលខកខានមិនបានសងបំណុល លើសពី ៩០ ថ្ងៃ ។

*(ខ) ចំណូលពីសកម្មភាពផ្សេងៗរបស់ធនាគារ*

ចំណូលពីសកម្មភាពផ្សេងៗរបស់ធនាគារ ត្រូវបានបង្គរដោយប្រើមូលដ្ឋាន ដូចខាងក្រោម:

១. កំរៃលើការចាត់ចែងផ្តល់ឥណទាន និងកំរៃជើងសារលើសេវាកម្ម និងឥណទានដែលបានផ្តល់ទៅឱ្យអតិថិជន ត្រូវបានទទួលស្គាល់នៅពេលប្រតិបត្តិការកើតឡើង ។

២. កំរៃលើកិច្ចសន្យា និងកំរៃការធានាលើសេវាកម្មផ្សេងៗ និងឧបករណ៍ហិរញ្ញវត្ថុនានាដែលផ្តល់អោយ អតិថិជន ត្រូវបានទទួលស្គាល់ជាចំណូល ក្នុងរយៈពេលប្រតិបត្តិ និងក៏រឹតឥណទានបន្ថែម ផ្តល់ឱ្យ ។

៣. កំរៃសេវាកម្ម និងកំរៃរត់ការ ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានបំពេញ ។

៤. ភាគលាភ ត្រូវបានទទួលស្គាល់ នៅពេលដែលសិទ្ធិរបស់ធនាគារក្នុងការទូទាត់សងត្រូវបានបង្កើតឡើង ។

*(គ) ចំណាយលើការប្រាក់*

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់អតិថិជន គណនីទូទាត់របស់ធនាគារផ្សេងៗ ហើយនឹងប្រាក់កម្ចី ត្រូវបាន ទទួលស្គាល់តាមមូលដ្ឋានបង្គរប្រចាំថ្ងៃ ។

### ២.៤.១៦ ភតិសន្យា

ការចំណាយទៅលើភតិសន្យា ត្រូវបានគិតបញ្ចូលទៅក្នុង របាយការណ៍លទ្ធផលតាមអត្រាថេរ ស្របតាមថេរវេលានៃការជួល ។

### ២.៤.១៧ សម្ព័ន្ធញាតិ

ភាគីដែលចាត់ទុកថាសម្ព័ន្ធញាតិ លុះត្រាធនាគារមានលទ្ធភាពគ្រប់គ្រងផ្ទាល់ ឬ ប្រយោលលើភាគីផ្សេង ទៀត ឬមានឥទ្ធិពលយ៉ាងសំខាន់ក្នុងការធ្វើសេចក្តីសំរេចចិត្តផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ច្រាសមកវិញ ប្រសិនបើ ធនាគារ

និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលជាសំខាន់ ។ សម្ព័ន្ធញាតិអាចជា រូបវន្តបុគ្គល ឬ នីតិបុគ្គល ហើយក៏បានរួមបញ្ចូលផងទាំងបុគ្គលជិតស្និតនៅក្នុងសមាជិកគ្រួសារផងដែរ ។

សម្ព័ន្ធញាតិ ដែលត្រូវបានកំនត់ក្នុងច្បាប់ស្តីពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា រួមមាន:

ភាគីសម្ព័ន្ធញាតិ ដូចដែលបានកំណត់ក្នុងមាត្រាទី ៤៩ និង ៥០ នៃច្បាប់ស្តីពី ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ រួមមានដូចខាងក្រោម :

ក- បុគ្គលទាំងឡាយណាដែលកាន់កាប់ដោយផ្ទាល់ ឬ ដោយប្រយោលចំនួន ១០% យ៉ាងតិចនៃដើមទុន ឬ នៃសិទ្ធិបោះឆ្នោត ។

ខ- ក្រុមហ៊ុនណាដែលគ្រឹះស្ថានចំណុះច្បាប់នេះកាន់កាប់នៅក្នុងដើមទុនដោយផ្ទាល់ ឬដោយប្រយោលនូវភាគកម្មយ៉ាងតិចស្មើនឹង ១០% នៃដើមទុន ឬតំណាងយ៉ាងតិច ១០%នៃសិទ្ធិបោះឆ្នោត។

គ-បុគ្គលណាដែលចូលរួមក្នុងអភិបាល ការដឹកនាំ ការកាន់កាប់ ឬការត្រួតពិនិត្យផ្ទៃក្នុង ។

ឃ- រាល់សវនករខាងក្រៅ ។

## ២.៤.១៨ ប្រតិបត្តិការ និងការប្រែសម្រួលរូបិយប័ណ្ណបរទេស

ធនាគារ រក្សាប្រព័ន្ធគណនេយ្យ និងកត់ត្រាគ្រប់ប្រតិបត្តិការទាំងអស់ ជារូបិយប័ណ្ណជាក់ស្តែង ។ ទ្រព្យសកម្ម និង ទ្រព្យអកម្ម ដែលជារូបិយប័ណ្ណបរទេស ("រ.ប") នាចុងការិយបរិច្ឆេទបញ្ចប់ ត្រូវបានប្រែសម្រួលឡើង វិញជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់ដែលកំណត់នៅកាលបរិច្ឆេទនៃរបាយការណ៍ សូមមើលកំណត់ សំគាល់លេខ ២.១ ។ ចំណូល និង ចំណាយ ដែលកើតឡើងជា រ.ប ត្រូវបានប្តូរជាប្រាក់ដុល្លារអាមេរិក នាចុងខែ ដោយប្រើអត្រាប្តូរប្រាក់មធ្យម សមស្រប ជាជាងអត្រាប្តូរប្រាក់ដែលកំណត់នាកាលបរិច្ឆេទនៃ ប្រតិបត្តិការ ។

## ២.៤.១៩ ទ្រព្យសកម្មដែលស្ថិតក្រោមកិច្ចសន្យាធានា

ទ្រព្យសកម្មដែលផ្ញើរក្សាទុក ឬក្នុងសមាសភាពជាទ្រព្យដាក់ធានា គឺមិនត្រូវបានបង្ហាញក្នុងរបាយការណ៍ ហិរញ្ញវត្ថុទេ ពីព្រោះទ្រព្យទាំងនេះ មិនមែនជាទ្រព្យសកម្មរបស់ធនាគារឡើយ ។

## ២.៤.២០ ការកាត់ខ្ទង់នៃចំនួនទឹកប្រាក់

ចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ បានត្រូវបានកាត់ខ្ទង់ជាចំនួនគត់ឯកតាដុល្លារអាមេរិក ចំពោះចំនួនទឹកប្រាក់ដុល្លារអាមេរិក និង ឯកតាពាន់រៀល ចំពោះចំនួនទឹកប្រាក់រៀល ។

## ២.៤.២១ តួលេខប្រៀបធៀប

តួលេខប្រៀបធៀបមួយចំនួនត្រូវបានចាត់ថ្នាក់ឡើងវិញ ដើម្បីអោយស្របតាមការបង្ហាញ សំរាប់ការិយបរិច្ឆេទ បច្ចុប្បន្ន ។

## ៣. សាច់ប្រាក់

| | ៣១ធ្នូ២០០៩ ដុល្លារអាមេរិក | ៣១ធ្នូ២០០៩ សមមូលពាន់រៀល (សំគាល់២.១) | ៣១កក្កដា២០០៩ ដុល្លារអាមេរិក | ៣១កក្កដា២០០៩ សមមូលពាន់រៀល (សំគាល់២.១) |
|---|---|---|---|---|
| ដុល្លារអាមេរិក | ១២១.២៦៧ | ៥០៥.៥៦២ | ១០៨.២០៩ | ៤៥៣.៥០៤ |
| ខ្មែររៀល | ១៤.៤៩០ | ៦០.៤០៩ | ១១.៨៤៧ | ៤៩.៦៥២ |
| រូបិយប័ណ្ណដទៃ | ១៦.៨៨៦ | ៧០.៣៩៩ | ៧០០ | ២.៩៣៤ |
| | **១៥២.៦៤៣** | **៦៣៦.៣៧០** | **១២០.៧៥៦** | **៥០៦.០៩០** |

សំរាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និង សាច់ប្រាក់ប្រហាក់ប្រហែលរួមមានៈ

| | ៣១ធ្នូ២០០៩ ដុល្លារអាមេរិក | ៣១ធ្នូ២០០៩ សមមូលពាន់រៀល (សំគាល់២.១) | ៣១កក្កដា២០០៩ ដុល្លារអាមេរិក | ៣១កក្កដា២០០៩ សមមូលពាន់រៀល (សំគាល់២.១) |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ១៥២.៦៤៣ | ៦៣៦.៣៧០ | ១២០.៧៥៦ | ៥០៦.០៩០ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា-គណនីចរន្ត | ៤៤.៥១៨.៦២០ | ១៨៥.៥៩៨.១២៥ | ៤.០៦០ | ១៧.០១៣ |
| សមតុល្យនៅធនាគារដទៃ- គណនីចរន្តនិងបញ្ញើ (កាលកំណត់តិចជាង៣ខែ) | ២១.០៧៣.០៥៤ | ៨៧.៨៥៣.៥៦២ | ៤.០៣៦ | ១៦.៩១៤ |
| | **៦៥.៧៤៤.៣១៧** | **២៧៤.០៨៨.០៥៧** | **១២៨.៨៥២** | **៥៤០.០១៧** |

BIDC Be your side, by your hand

## ៤. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | ៣១ធ្នូ២០០៩ ដុល្លារអាមេរិក | ៣១ធ្នូ២០០៩ សមមូលពាន់រៀល (សំគាល់២.១) | ៣១កក្កដា២០០៩ ដុល្លារអាមេរិក | ៣១កក្កដា២០០៩ សមមូលពាន់រៀល (សំគាល់២.១) |
|---|---|---|---|---|
| គណនីចរន្តធនាគារជាតិនៃកម្ពុជា | | | | |
| ខ្មែររៀល | ២៣.០០២ | ៩៥.៨៩៤ | ៤១៨ | ១.៧៥២ |
| ដុល្លារអាមេរិក | ៤៤.៤៩៥.៦១៨ | ១៨៥.៥០២.២៣១ | ៣.៦៤២ | ១៥.២៦១ |
| **បញ្ញើតាមតម្រូវការ** | | | | |
| ប្រាក់តម្កល់ធានាលើដើមទុន - ដុល្លាររអាមេរិក | ៧.០០០.០០០ | ២៩.១៨៣.០០០ | ១.៣៥០.០០០ | ៥.៦៥៧.៨៥០ |
| ប្រាក់បំរុងកាតព្វកិច្ច - ខ្មែររៀល | ២.៣៩៨ | ១០.០០០ | ២.៣៩៨ | ១០.០៥២ |
| ប្រាក់បំរុងកាតព្វកិច្ច -ដុល្លារអាមេរិក | ៧៣០.០០០ | ៣.០៤៣.៣៧០ | ២៥.០០០ | ១០៤.៧៧៥ |
| | **៥២.២៥១.០១៨** | **២១៧.៨៣៤.៤៩៥** | **១.៣៨១.៤៥៨** | **៥.៧៨៩.៦៩០** |

*(ក) ប្រាក់ តម្កល់ធានាលើដើមទុន*

*ប្រាក់តម្កល់ធានាលើដើមទុនសំរាប់ធនាគារ*

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១-១៣៦ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១ គ្រប់ធនាគារទាំងអស់ត្រូវបានតម្រូវអោយរក្សាប្រាក់តំកល់តាមច្បាប់ចំនួន ១០% នៃដើមទុនចុះបញ្ជី ។ ប្រាក់តម្កល់នេះ គឺមិនអាច ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារបានឡើយ ប៉ុន្តែធនាគារអាចដកយកវិញ បាននៅពេលដែល ធនាគារសំរេចចិត្តឈប់ធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

*(ខ) ប្រាក់បំរុងកាតព្វកិច្ច*

តាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០៩-០៧៥ ចុះ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ ធនាគារ តម្រូវអោយរក្សាចំនួនទឹកប្រាក់បំរុងជាក់លាក់មួយនៅធនាគារជាតិនៃកម្ពុជា ក្នុងទំរង់ជាប្រាក់បញ្ញើ កាតព្វកិច្ច គណនាតាមអត្រា ៨ ភាគរយ និង ១២ ភាគរយ នៃប្រាក់បញ្ញើអតិថិជន ជារូបិយប័ណ្ណរៀល និងជារូបិយប័ណ្ណបរទេសរៀងគ្នា។

ការវិនិច្ឆ័យបន្ថែមទៅលើប្រាក់បញ្ញើ និង ប្រាក់តំកល់របស់ធនាគារផ្សេងទៀត មានដូចខាងក្រោមៈ

(ក). ការវិនិច្ឆ័យតាមរយៈកាលអវសាន យោងទៅតាមកំណត់បង្ហាញលេខ ២៤.២ ទៅលើហានិភ័យសាច់ប្រាក់ងាយស្រួល

(ខ). តាមអត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់បញ្ញើ និង ប្រាក់តំកល់នៅធនាគារផ្សេងត្រូវបានសង្ខេបដូចខាងក្រោមៈ

| | *៣១ធ្នូ២០០៩* | *៣១កក្កដា២០០៩* |
|---|---|---|
| ប្រាក់តម្កល់ធានាលើដើមទុន - ដុល្លារអាមេរិក | ០,២៨% | ០,២៨% |
| ប្រាក់បំរុងកាតព្វកិច្ច -ដុល្លារអាមេរិក និងខ្មែររៀល | គ្មាន | គ្មាន |
| គណនីចរន្ត | គ្មាន | គ្មាន |

BIDC Be your side, by your hand

## ៥. សមតុល្យនៅធនាគារផ្សេងៗ

| | ៣១ធ្នូ២០០៩ ដុល្លារអាមេរិក | ៣១ធ្នូ២០០៩ សមមូលពាន់រៀល (សំគាល់២.១) | ៣១កក្កដា២០០៩ ដុល្លារអាមេរិក | ៣១កក្កដា២០០៩ សមមូលពាន់រៀល (សំគាល់២.១) |
|---|---|---|---|---|
| **ធនាគារក្នុងស្រុក** | | | | |
| ធនាគារអេស៊ីលីដាភីអិលស៊ី-ខ្មែររៀល | ២១២ | ៨៨៥ | ២១២ | ៨៨៨ |
| ធនាគារអេស៊ីលីដាភីអិលស៊ី - ដុល្លារអាមេរិក | ៨០៦.៩៦៩ | ៣.៣៦៤.២៥៤ | ១.១២០ | ៤.៦៩៥ |
| ធនាគារកាណាឌីយ៉ាភីអិលស៊ី - ដុល្លារអាមេរិក | ២០៨.៣៩៣ | ៨៦៨.៧៨៩ | - | - |
| **ធនាគារក្រៅប្រទេស** | | | | |
| ធនាគារដុងអា - ដុល្លារអាមេរិក | ៥.១១៩ | ២១.៣៤២ | ២.១៤៩ | ៩.០០៤ |
| ធនាគារដុងអា - វៀតណាមដុង | ៥៦១ | ២.៣៣៩ | ៥៥៥ | ២.៣២៧ |
| ធនាគារវិនិយោគនិងអភិវឌ្ឍន៍ វៀតណាម(ស្នាក់ការកណ្តាល) - ដុល្លារអាមេរិក | ៥.១៥៦.០៧០ | ២១.៤៩៥.៦៥៦ | - | - |
| ធនាគារវិនិយោគនិងអភិវឌ្ឍន៍ វៀតណាម(សាខាហូជីមិញ) - ដុល្លារអាមេរិក | ៩៨៩ | ៤.១២១ | - | - |
| ធនាគារវិនិយោគនិងអភិវឌ្ឍន៍ វៀតណាម(សាខាហូជីមិញ) - វៀតណាមដុង | ១៤.៨៩៤.៧៤១ | ៦២.០៩៦.១៧៦ | - | - |
| | **២១.០៧៣.០៩៤** | **៨៧.៨៥៣.៦៦២** | **៤.០៣៦** | **១៦.៩១៤** |

**អត្រាការប្រាក់:** អត្រាការប្រាក់នៅសមតុល្យនៅធនាគារផ្សេងៗត្រូវបានសង្ខេបដូចខាងក្រោម:

| | ៣១ធ្នូ២០០៩ | ៣១កក្កដា២០០៩ |
|---|---|---|
| ធនាគារអេស៊ីលីដាភីអិលស៊ី-ខ្មែររៀល | គ្មាន | គ្មាន - ១,០០% |
| ធនាគារអេស៊ីលីដាភីអិលស៊ី - ដុល្លារអាមេរិក | គ្មាន | គ្មាន |
| ធនាគារកាណាឌីយ៉ាភីអិលស៊ី - ដុល្លារអាមេរិក | គ្មាន | គ្មាន |
| ធនាគារដុងអា - ដុល្លារអាមេរិក | ០,៥០% | ០,៥០% |
| ធនាគារដុងអា - វៀតណាមដុង | ៣,៦០% | ៣,០០% |
| ធនាគារវិនិយោគនិងអភិវឌ្ឍន៍នៃ ប្រទេសវៀតណាម(ស្នាក់ការកណ្តាល) -ដុល្លារអាមេរិក | ០,១០% | គ្មាន |
| ធនាគារវិនិយោគនិងអភិវឌ្ឍន៍នៃ ប្រទេសវៀតណាម(សាខាហូជីមិញ) - ដុល្លារអាមេរិក | ០,១០% | គ្មាន |
| ធនាគារវិនិយោគនិងអភិវឌ្ឍន៍នៃ ប្រទេសវៀតណាម(សាខាហូជីមិញ) - វៀតណាមដុង | ២,៤០% | គ្មាន |

## ៦. ប្រាក់បញ្ញើ និងគណនីរបស់ធនាគារផ្សេងៗ

| | ៣១ធ្នូ២០០៩ ដុល្លារអាមេរិក | ៣១ធ្នូ២០០៩ សមមូលពាន់រៀល (សំគាល់២.១) | ៣១កក្កដា២០០៩ ដុល្លារអាមេរិក | ៣១កក្កដា២០០៩ សមមូលពាន់រៀល (សំគាល់២.១) |
|---|---|---|---|---|
| ធនាគារឡាវវៀត(សាខាហូជីមិញ) | ៤៩.០០៤ | ២០៤.២៩៥ | - | - |
| ធនាគារវិនិយោគ និងអភិវឌ្ឍន៍ វៀតណាម(សាខាSGD2) | ១០.០០៩.០០០ | ៤១.៧២៧.៩២១ | - | - |
| ធនាគារវិនិយោគ និងអភិវឌ្ឍន៍ វៀតណាម(សាខាNKKN) | ៤.៩៥០.០០០ | ២០.៦៣៦.៥៥០ | - | - |
| | **១៥.០០៨.០០៤** | **៦២.៥៦៨.៣៦៦** | **-** | **-** |

## ៧. ឥណទាន និង ប្រាក់បុរេប្រទានឱ្យអតិថិជន

| | ៣១ធ្នូ២០០៩ ដុល្លារអាមេរិក | ៣១ធ្នូ២០០៩ សមមូលពាន់រៀល (សំគាល់២.១) | ៣១កក្កដា២០០៩ ដុល្លារអាមេរិក | ៣១កក្កដា២០០៩ សមមូលពាន់រៀល (សំគាល់២.១) |
|---|---|---|---|---|
| ឥណទានដុល | | | | |
| ឥណទានកាលកំណត់ | ៨៤.២០៣.៦៧៨ | ៣៥១.០៤៥.១៣៣ | - | - |
| ចំណូលត្រូវបានផ្សេងៗ | | | | |
| ចំណូលត្រូវបានពីការប្រាក់បង្គរ | ៦២.៣៥០ | ២៥៩.៩៤០ | - | - |
| ការប្រាក់ព្យួរទុក | - | - | - | - |
| សំវិធានធនលើឥណទាននិងបុរេប្រទានបាត់បង់(*) | - | - | - | - |
| **ឥណទាន និង ប្រាក់បុរេប្រទានឱ្យអតិថិជន** | **៨៤.២៦៦.០២៨** | **៣៥១.៣០៥.០៧៣** | **-** | **-** |

(*) ប្រកាសលេខ ធ៧-៩-០៧៤ ចុះ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ តំរូវអោយធនាគារ ទាំងអស់នៅប្រទេសកម្ពុជា យកសំវិធានធនទូទៅស្មើនឹង ១% នៃចំណាត់ថ្នាក់ឥណទានដុល "ឥណទានស្តង់ដារ" ។ ទោះយ៉ាងណា ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាត BIDC រាប់បញ្ចូលនូវសំវិធានធនទូទៅ សំរាប់កាលបរិច្ឆេទ ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ នោះទេ ដោយយោងតាមប្រកាសរបស់ ធនាគារជាតិនៃកម្ពុជា លេខ ធ៧-១០-១៥ ចុះ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១០។

ការវិភាគបន្ថែមទៅលើ ឥណទាន និង ប្រាក់បុរេប្រទានមានដូចខាងក្រោម:

(ក) សំណុំឯកសារឥណទានត្រូវបានចាត់ថ្នាក់ដូចខាងក្រោម:

| | ៣១ធ្នូ២០០៩ ដុល្លារអាមេរិក | ៣១ធ្នូ២០០៩ សមមូលពាន់រៀល (សំគាល់២.១ | ៣១កក្កដា២០០៩ ដុល្លារអាមេរិក | ៣១កក្កដា២០០៩ សមមូលពាន់រៀល (សំគាល់២.១ |
|---|---|---|---|---|
| ឥណទានស្តង់ដារ | | | | |
| មានវត្ថុធានា | ២០.៣៧២.៦៨៦ | ៨៤.៩៣៣.៧២៧ | - | - |
| មិនមានវត្ថុធានា | ៦៣.៨៣០.៩៩២ | ២៦៦.១១១.៤០៦ | - | - |
| | **៨៤.២០៣.៦៧៨** | **៣៥១.០៤៥.១៣៣** | **-** | **-** |

(ខ) សំរាប់ការវិភាគលើឥណទាន និង ប្រាក់បុរេប្រទានតាមរយៈកាលអវសានយោងទៅតាមកំណត់សំគាល់ លេខ ២៤.២ អំពី ការវិភាគសាច់ប្រាក់ងាយស្រួល។

(គ). សំរាប់ការវិភាគលើឥណទាន និង ប្រាក់បុរេប្រទានតាមរយៈរូបិយប័ណ្ណ យោងទៅកំណត់បង្ហាញលេខ ២៤ អំពី ហានិភ័យនៃការប្តូរប្រាក់បរទេស។

(ឃ) ការវិភាគទៅលើឥណទាននិងប្រាក់បុរេប្រទានតាមប្រភេទនៃសេដ្ឋកិច្ចមានដូចខាងក្រោម:

| | ៣១ធ្នូ២០០៩ ដុល្លារអាមេរិក | ៣១ធ្នូ២០០៩ សមមូលពាន់រៀល (សំគាល់២.១) | ៣១កក្កដា២០០៩ ដុល្លារអាមេរិក | ៣១កក្កដា២០០៩ សមមូលពាន់រៀល (សំគាល់២.១) |
|---|---|---|---|---|
| ឥណទានពាណិជ្ជកម្ម | ៨៣.៩១៧.២២១ | ៣៤៩.៨៥០.៨៩៦ | - | - |
| ឥណទានប្រើប្រាស់ | ២៨៦.៤៥៧ | ១.១៩៤.២៣៧ | - | - |
| ឥណទានដុលសរុប | **៨៤.២០៣.៦៧៨** | **៣៥១.០៤៥.១៣៣** | - | - |

BIDC Be your side, by your hand

(ង) ការវិភាគទៅលើឥណទាន និង ប្រាក់បុរេប្រទានតាមប្រភេទនៃឧស្សាហកម្ម មានដូចខាងក្រោម:

| | *៣១ធ្នូ២០០៩* | *៣១ធ្នូ២០០៩* | *៣១កក្កដា២០០៩* | *៣១កក្កដា២០០៩* |
|---|---|---|---|---|
| | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* | *ដុល្លារអាមេរិក* | *សមមូលពាន់រៀល* |
| | | *(សំគាល់២.១)* | | *(សំគាល់២.១)* |
| កសិកម្ម | ៩០០.០០០ | ៣.៧៥២.១០០ | - | - |
| រោងចក្រ | ១៩.៦៦៩.៩១៨ | ៨១.៩៨៧.២១០ | - | - |
| សំណង់ | ៥.៩០០.៣៥៩ | ២៤.៥៩៨.៥៩៨ | - | - |
| ពាណិជ្ជកម្មលក់ដុំលក់រាយ | ២.៦៨៧.៥៧៧ | ១១.២០៤.៥១០ | - | - |
| ទូរគមនាគមន៍ | ២១.៨៩៥.០២៣ | ៩១.២៨០.៣៩៣ | - | - |
| ឯកត្តជន | ២៨៦.៤៥៧ | ១.១៩៤.២៣៧ | - | - |
| ការជួញដូរអចលនទ្រព្យ | ២២.៨៦៨.៣៤៤ | ៩៥.៣៣៨.១២៥ | - | - |
| ផ្សេងៗ | ១០.០០០.០០០ | ៤១.៦៩០.០០០ | - | - |
| ឥណទានដុលសរុប | **៨៤.២០៣.៦៧៨** | **៣៥១.០៤៥.១៣៣** | **-** | **-** |

BIDC Be your side, by your hand

(ច) ការវិភាគផ្សេងៗលើឥណទាន និង ប្រាក់បុរេប្រទានតាមប្រភេទ និវាសនជន សម្ព័ន្ធភាព ហានិភ័យ អត្រាការប្រាក់រួមមាន:

| | *៣១ធ្នូ២០០៩* *ដុល្លារអាមេរិក* | *៣១ធ្នូ២០០៩* *សមមូលពាន់រៀល* *(សំគាល់២.១)* | *៣១កក្កដា២០០៩* *ដុល្លារអាមេរិក* | *៣១កក្កដា២០០៩* *សមមូលពាន់រៀល* *(សំគាល់២.១)* |
|---|---|---|---|---|
| និវាសនភាព | | | | |
| និវាសនជន | ២០.៣៧២.៦៨៦ | ៨៤.៩៣៣.៧២៦ | - | - |
| អនិវាសនជន | ៦៣.៨៣០.៩៩២ | ២៦៦.១១១.៤០៧ | - | - |
| | **៨៤.២០៣.៦៧៨** | **៣៥១.០៤៥.១៣៣** | **-** | **-** |
| សម្ព័ន្ធភាព | | | | |
| ភាគីសម្ព័ន្ធញាតិ | - | - | - | - |
| ភាគីមិនមែនសម្ព័ន្ធញាតិ | ៨៤.២០៣.៦៧៨ | ៣៥១.០៤៥.១៣៣ | - | - |
| | **៨៤.២០៣.៦៧៨** | **៣៥១.០៤៥.១៣៣** | **-** | **-** |
| ហានិភ័យ | | | | |
| ធំ | ៦៨.៨៤៧.០០០ | ២៨៧.០២៣.១៤៤ | - | - |
| មិនធំ | ១៥.៣៥៦.៦៧៨ | ៦៤.០២១.៩៨៩ | - | - |
| | **៨៤.២០៣.៦៧៨** | **៣៥១.០៤៥.១៣៣** | **-** | **-** |

| លំដាប់អត្រាការប្រាក់ពី: | *៣១ធ្នូ២០០៩* | *៣១កក្កដា២០០៩* |
|---|---|---|
| ឥណទានមានកាលកំណត់ | ៦,៣០% - ១០,៥០% | ៦,៣០% - ១០,៥០% |

BIDC Be your side, by your hand

## ៨. ទ្រព្យ និងបរិក្ខារ

បំរែបំរួលនៃ ទ្រព្យ និងបរិក្ខារចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ រួមមាន៖

| | ដី អាគារ | ការជួសជុលកែលំអរបស់អគារ | សម្ភារៈការិយាល័យ និងគ្រឿងបំពាក់ | សំភារៈអេឡិចត្រូនិច | យានយន្ត | សំណង់កំពុងសាងសង់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| តម្លៃដើម | | | | | | | |
| ត្រឹមថ្ងៃទី១ខែសីហាឆ្នាំ២០០៩ | - | ៩១.៥១៩ | ៣៤០.៩៦៩ | ២៥៩.៧៣៦ | - | - | ៦៩២.២២៤ |
| ការបន្ថែមក្នុងគ្រា | - | - | ១០.១៨៥ | ៦.១៧៥ | ១៦៣.១៥០ | - | ១៧៩.៥១០ |
| លុបចោល | - | - | (៥៦៥) | - | - | - | (៥៦៥) |
| | | **៩១.៥១៩** | **៣៥០.៥៨៩** | **២៦៥.៩១១** | **១៦៣.១៥០** | | **៨៧១.១៦៩** |
| **ដក៖ រំលស់បង្គរ** | | | | | | | |
| ត្រឹមថ្ងៃទី១ខែសីហាឆ្នាំ២០០៩ | - | ៥.២៧០ | ១៥១.២១៥ | ១០៧.៥០៦ | - | - | ២៦៣.៩៩១ |
| រំលស់ក្នុងការិយបរិច្ឆេទ | - | ១.១៤៤ | ៣៥.៦១៤ | ២៧.២៤២ | ៧.៨២២ | - | ៧១.៨២២ |
| លុបចោល | - | - | - | - | - | - | - |
| ត្រឹមថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៩ | - | **៦.៤១៤** | **១៨៦.៨២៩** | **១៣៤.៧៤៨** | **៧.៨២២** | - | **៣៣៥.៨១៣** |
| **តម្លៃសុទ្ធ** | | | | | | | |
| ត្រឹមថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៩ | - | **៨៥.១០៥** | **១៦៣.៧៦០** | **១៣១.១៦៣** | **១៥៥.៣២៨** | - | **៥៣៥.៣៥៦** |
| ត្រឹមថ្ងៃទី១ខែសីហាឆ្នាំ២០០៩ | - | **៨៦.២៤៩** | **១៨៩.៧៥៤** | **១៥២.២៣០** | - | - | **៤២៨.២៣៣** |
| តំលៃសមមូលពាន់រៀល (សំគាល់២.១) | | | | | | | |
| ត្រឹមថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៩ | - | **៣៥៤.៨០៣** | **៦៨២.៧១៤** | **៥៤៦.៨១៩** | **៦៤៧.៥៦២** | - | **២.២៣១.៨៩៨** |
| ត្រឹមថ្ងៃទី១ខែសីហាឆ្នាំ២០០៩ | - | **៣៦១.៤៦៩** | **៧៩៩.២៥៩** | **៦៣៧.៩៩៦** | - | - | **១.៧៩៩.៧២៤** |

## ៩. ទ្រព្យអរូបិយ

បំរែបំរួលនៃទ្រព្យអរូបិយថ្ងៃទី១ខែសីហាឆ្នាំ២០០៩ដល់ថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៩រួមមាន:

| | *កម្មវិធីកុំព្យូទ័រ* | *ចំណាយមុនដំណើរការ* | *សរុប* |
|---|---|---|---|
| | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* | *ដុល្លារអាមេរិក* |
| **តម្លៃដើម** | | | |
| ត្រឹមថ្ងៃទី១ខែសីហាឆ្នាំ២០០៩ | ៤៥៣.៦៣៩ | ២២៣.៣៧៦ | ៦៧៧.០១៥ |
| ការបន្ថែមក្នុងគ្រា | ២.៨៥០ | ៤៣.២៦០ | ៤៦.១១០ |
| លុបចោល | - | - | - |
| ត្រឹមថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៩ | **៤៥៦.៤៨៩** | **២៦៦.៦៣៦** | **៧២៣.១២៥** |
| **ដក: រំលស់បង្គរ** | | | |
